# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**កំពង់ផែស្វយ័តភ្នំពេញ**
**អង្គភាពលទ្ធកម្ម**
លេខ......១៥៦/២២......លក-ក.ស.ភ.

# ឯកសារដេញថ្លៃ
## ស្តីពី
### ការខាររូស គំនូសផ្លូវ RTG គំនូសលេខ Row& Bay គំនូសទីតាំងដាក់ កុងតឺន័រ នៅលើទីលាន ជំហានទី១ ជំហានទី២ ស្ថិតនៅចំណតផែកុងតឺន័រ LM១៧

ឈ្មោះក្រុមហ៊ុន/សហគ្រាស : ..............................................................................

អាសយដ្ឋានទាក់ទង : ........................................................................................

..............................................................................................................................

ទូរស័ព្ទ : .......................................... ទូរសារ : ...........................................................

គេហទំព័រ : ......................................................................................................

**កាលបរិច្ឆេទទទួលសំណើដេញថ្លៃ រៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃទី ........... ខែ ............. ឆ្នាំ២០២២**
**កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃ នៅម៉ោង ............. ថ្ងៃទី ........ខែ..........ឆ្នាំ២០២២**

# មាតិកា



| ល.រ | បរិយាយ | ទំព័រ |
|---|---|---|
| ១. | សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមដេញថ្លៃ | ១ |
| ២. | សេចក្តីណែនាំចំពោះអ្នកដេញថ្លៃ | ២-៨ |
| ៣. | លក្ខខណ្ឌនៃកិច្ចសន្យា | ៩-១៥ |
| ៤. | គំនូសប្លង់ (ឧបសម្ព័ន្ធទី១) | ១៦-១៩ |
| ៥. | លំអិតលក្ខណៈបច្ចេកទេស (ឧបសម្ព័ន្ធទី២) | ២០ |
| ៦. | ទម្រង់លិខិតពាក្យសុំដេញថ្លៃ (ឧបសម្ព័ន្ធទី៣) | ២១ |
| ៧. | សេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មរបស់អ្នកដេញថ្លៃ | ២២ |
| ៨. | បញ្ជីប៉ាន់តម្លៃសរុប (ឧបសម្ព័ន្ធទី៤) | ២៣ |
| ៩. | បញ្ជីប៉ាន់តម្លៃពលកម្ម (ឧបសម្ព័ន្ធទី៤.១) | ២៤ |
| ១០. | បញ្ជីប៉ាន់តម្លៃសម្ភារ (ឧបសម្ព័ន្ធទី៤.២) | ២៥ |
| ១១. | ប្រតិទិនការងារ (ឧបសម្ព័ន្ធទី៥) | ២៦ |
| ១២. | លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ (ឧបសម្ព័ន្ធទី៦) | ២៧ |
| ១៣. | លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា (ឧបសម្ព័ន្ធទី៧) | ២៨ |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH AUTONOMOUS PORT

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ.៣០៣/២២ក. ស. ភ.

ថ្ងៃសុក្រ ១៥កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព. ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០២២

# សេចក្តីជូនដំណឹងលើកទី២

## ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃ
## ការងារគូស គំនូសផ្លូវ RTG គំនូសលេខ Row& Bay គំនូសទីតាំងដាក់ កុងតឺន័រ នៅលើទីលាន ជំហានទី១ ជំហានទី២ ស្ថិតនៅចំណតផែកុងតឺន័រ LM១៧

កំពង់ផែស្វយ័តភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា កំពង់ផែស្វយ័តភ្នំពេញនឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការងារគូស គំនូសផ្លូវ RTG គំនូសលេខ Row& Bay គំនូសទីតាំងដាក់កុងតឺន័រ នៅលើទីលាន ជំហានទី១ ជំហានទី២ ស្ថិតនៅចំណតផែកុងតឺន័រ LM១៧។

កំពង់ផែស្វយ័តភ្នំពេញ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ឯកសារដេញថ្លៃមានដាក់លក់ នៅអង្គភាពលទ្ធកម្ម កំពង់ផែស្វយ័តភ្នំពេញដែលមានអាសយដ្ឋានអគារលេខ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពី**ថ្ងៃទី**១៥......**ខែ**សីហា **ឆ្នាំ២០២២** តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០១០ ៨៨៨ ៦៩១)។

កាលបរិច្ឆេទឈប់ទទួលពាក្យសំណើដេញថ្លៃនៅម៉ោង១៨:៣០ ថ្ងៃទី២៩...ខែសីហា....ឆ្នាំ២០២២។ ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ **វេលាម៉ោង** ១៨:០០**នាទី ថ្ងៃទី**២៩...**ខែ**.សីហា........**ឆ្នាំ២០២២។**

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាប្រធានអគ្គនាយក**
**និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ហ៊ី-បាទី**

<u>ចម្លងជូន</u>
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ

# សេចក្តីណែនាំចំពោះអ្នកដេញថ្លៃ

## ១- វិសាលភាព

កំពង់ផែស្វយ័តភ្នំពេញមានបំណងដាក់ឱ្យដេញថ្លៃការងារគូស គំនូសផ្លូវ RTG គំនូសលេខ Row& Bay គំនូសទីតាំងដាក់កុងតឺន័រនៅលើទីលាន ជំហានទី១ ជំហានទី២ ស្ថិតនៅចំណតផែកុងតឺន័រLM១៧។ អ្នកដេញថ្លៃឈ្នះនឹងត្រូវអនុវត្តការងារគូស គំនូសផ្លូវ RTG គំនូសលេខ Row& Bay គំនូសទីតាំងដាក់កុងតឺន័រនៅលើទីលាន ជំហានទី១ ជំហានទី២ ស្ថិតនៅចំណតផែកុងតឺន័រLM១៧ បានចប់សព្វគ្រប់យ៉ាងយូរក្នុងរយៈពេល ៥០(ហាសិប)ថ្ងៃ ក្រោយពីកិច្ចសន្យាចូលជាធរមាន។

## ២- ប្រភពឥណទាន

ប្រភពឥណទានសម្រាប់ការងារនេះ បានមកពីថវិកាកំពង់ផែស្វយ័តភ្នំពេញ។

## ៣- សិទ្ធិចូលរួមដេញថ្លៃ

ការដេញថ្លៃនេះបើកចំហចំពោះ ក្រុមហ៊ុន/សហគ្រាស ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែក្រុមហ៊ុន/សហគ្រាសដែលកំពុងស្ថិតក្នុងបញ្ជីខ្មៅ ឬ ត្រូវបានហាមឃាត់ដោយតុលាការ។

## ៤- សមាសធាតុនៃឯកសារដេញថ្លៃ

សមាសធាតុនៃឯកសារដេញថ្លៃរួមមាន ៖

១. សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមដេញថ្លៃ
២. សេចក្តីណែនាំចំពោះអ្នកដេញថ្លៃ
៣. លក្ខខណ្ឌនៃកិច្ចសន្យា
៤. គំនូសប្លង់
៥. លម្អិតលក្ខណៈបច្ចេកទេស
៦. ពាក្យសុំដេញថ្លៃ
៧. លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ
៨. លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា
៩. បញ្ជីប៉ាន់តម្លៃ "ពលកម្ម សម្ភារ សរុប"
១០. តារាងប្រតិទិនការងារសាងសង់

(៦–១០) ឧបសម្ព័ន្ធត្រូវបំពេញដោយអ្នកដេញថ្លៃ

អ្នកដេញថ្លៃត្រូវយកចិត្តទុកដាក់ពិនិត្យខ្លឹមសារ និងបំពេញឯកសារដេញថ្លៃឱ្យបានម៉ត់ចត់ហើយ សំណើដេញថ្លៃណា ដែលមិនឆ្លើយតបសមស្របតាមការតម្រូវគឺជាបុព្វបទនៃការពិនិត្យពិចារណាបដិសេធ។

## ៥- ឯកសារភ្ជាប់បញ្ជាក់លក្ខណសម្បត្តិអ្នកចូលរួមដេញថ្លៃ

អ្នកដេញថ្លៃ ត្រូវភ្ជាប់ជាមួយនូវឯកសារភស្តុតាង បង្ហាញពីលក្ខណសម្បត្តិរបស់ខ្លួនដូចខាងក្រោម៖

- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន ៣ច្បាប់
- ប័ណ្ណប៉ាតង់ ឆ្នាំដេញថ្លៃ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន ៣ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម អ.ត.ប(ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន ៣ច្បាប់
- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន ៣ច្បាប់
- វិញ្ញាបនបត្រប្រកបអាជីវកម្ម ចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

(ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន ៣ច្បាប់

- វិញ្ញាបនបត្រចុះបញ្ជីអ្នកទទួលការសាងសង់ ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចាប់ពីប្រភេទមធ្យមឡើងទៅ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន ៣ច្បាប់
- ឯកសារភស្តុតាងសម្រាប់បញ្ជាក់ពីសមត្ថភាព "ហិរញ្ញវត្ថុ បច្ចេកទេស បទពិសោធន៍" (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន ៣ច្បាប់

**៦- សំណើដេញថ្លៃមួយសម្រាប់អ្នកដេញថ្លៃតែមួយគត់**

ក្រុមហ៊ុន/សហគ្រាស ដែលមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ក្នុងករណីពិនិត្យឃើញថា ក្រុមហ៊ុន/សហគ្រាសដែលបានចូលរួមធ្វើការដេញថ្លៃ ជាក្រុមហ៊ុនមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ នឹងត្រូវបដិសេធដោយស្វ័យប្រវត្តិ។

**៧- ពាក្យសុំដេញថ្លៃ**

អ្នកដេញថ្លៃ ត្រូវបំពេញពាក្យសុំដេញថ្លៃដែលបញ្ជាក់ពីការប្តេជ្ញាចិត្តគោរពតាមកិច្ចសន្យាបញ្ជាក់ ពីការផ្តល់បញ្ជីប៉ាន់តម្លៃ និងរយៈពេលសាងសង់ ដែលបានផ្តល់នៅក្នុងឯកសារដេញថ្លៃ។

**៨- រូបិយប័ណ្ណដាក់ដេញថ្លៃ**

តម្លៃដាក់ដេញថ្លៃត្រូវជារូបិយប័ណ្ណជាតិ(ប្រាក់រៀល)។ ប្រសិនបើដាក់ជារូបិយប័ណ្ណបរទេសត្រូវប្តូរជាប្រាក់រៀលតាមអត្រាប្តូរប្រាក់របស់ធនាគារជាតិនាថ្ងៃបើកសំណើដេញថ្លៃ។

**៩- ការដាក់តម្លៃដេញថ្លៃ**

អ្នកដេញថ្លៃត្រូវបំពេញឱ្យបានត្រឹមត្រូវលើបញ្ជីប៉ាន់តម្លៃ "តម្លៃពលកម្ម តម្លៃសម្ភារ និងតម្លៃសរុប" (មើលឧបសម្ព័ន្ធទី ៨) ដោយរួមបញ្ចូល VAT១០%។

អ្នកដេញថ្លៃត្រូវដាក់តម្លៃដេញថ្លៃតែមួយគត់ ហើយជាតម្លៃថេរក្នុងរយៈពេលអនុវត្តកិច្ចសន្យារបស់ខ្លួន និងមិនមែនជាកម្មវត្ថុសម្រាប់ធ្វើការផ្លាស់ប្តូរទេ។ សំណើដេញថ្លៃណាមួយដែលដាក់តម្លៃដេញថ្លៃលើសពីមួយ ឬតម្លៃប្រែប្រួល ត្រូវចាត់ទុកជាមោឃៈ។

**១០- ការពិនិត្យទីតាំងសាងសង់**

អ្នកដេញថ្លៃត្រូវបានអនុញ្ញាតឱ្យចុះពិនិត្យទីតាំងជាមុន ដើម្បីទទួលបាននូវរាល់ព័ត៌មានដែលចាំបាច់សម្រាប់ការរៀបចំសំណើដេញថ្លៃ។

**១១- ការចំណាយសម្រាប់ការដេញថ្លៃ**

អ្នកដេញថ្លៃត្រូវទទួលបន្ទុករាល់ការចំណាយ ដែលពាក់ព័ន្ធជាមួយការរៀបចំ និងការដាក់សំណើដេញថ្លៃរបស់ខ្លួន។

**១២- ការចុះហត្ថលេខាលើសំណើដេញថ្លៃ**

អ្នកដេញថ្លៃត្រូវរៀបចំសំណើដេញថ្លៃជាបីច្បាប់ (ច្បាប់ដើមមួយច្បាប់ និងច្បាប់ចម្លងពីរច្បាប់)។ ក្នុងករណីមានភាពមិនស្របគ្នារវាងច្បាប់ដើម និងច្បាប់ចម្លងនោះ ច្បាប់ដើមជាឯកសារផ្លូវការ។ ច្បាប់ដើមត្រូវបំពេញដោយដៃ និងប្រើប្រាស់ទឹកខ្មៅដែលមិនអាចលុបជ្រះ ហើយត្រូវចុះហត្ថលេខាដោយអ្នកដេញថ្លៃ ឬអ្នកតំណាងដែលមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវ។ លិខិតផ្ទេរសិទ្ធិនេះ ត្រូវភ្ជាប់មកជាមួយសំណើដេញថ្លៃ។ គ្រប់ទំព័រនៃសំណើដេញថ្លៃ រួមទាំងទំព័រដែលបំពេញបន្ថែម ឬកែតម្រូវ ត្រូវចុះហត្ថលេខាសង្ខេបដោយអ្នកដែលត្រូវចុះហត្ថលេខាលើសំណើដេញថ្លៃ ដើម្បីចៀសវាងការក្លែងបន្លំ។

## ១៣- ការបិទភ្ជិត និងការធ្វើកំណត់សម្គាល់លើសំណើដេញថ្លៃ

ឯកសារច្បាប់ដើម និងច្បាប់ចម្លងត្រូវដាក់ក្នុងស្រោមសំបុត្របីផ្សេងគ្នាបិទភ្ជិត ដោយមានធ្វើសញ្ញាសម្គាល់លើស្រោមសំបុត្រថា "ច្បាប់ដើម" និង "ច្បាប់ចម្លង" រួចដាក់ក្នុងស្រោមសំបុត្ររួមធំមួយទៀតបិទភ្ជិត។ លើស្រោមសំបុត្រខាងក្នុង និងខាងក្រៅត្រូវសរសេរៈ

- មិនត្រូវបើកមើលមុនពេលវេលា និងកាលបរិច្ឆេទកំណត់សម្រាប់ការបើកសំណើដេញថ្លៃ
- ផ្ញើជូនអង្គភាពលទ្ធកម្ម (បញ្ចូលអាសយដ្ឋានដូចមានបញ្ជាក់ក្នុងឯកដេញថ្លៃ)
- ឈ្មោះ អាសយដ្ឋានអ្នកដេញថ្លៃ (បញ្ចូលឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ អ៊ីមែល របស់អ្នកដេញថ្លៃ)។

ប្រសិនបើស្រោមសំបុត្រណាមួយមិនបានបិទភ្ជិត និងមិនមានធ្វើកំណត់សម្គាល់ដូចការតម្រូវខាងលើទេនោះ គណៈកម្មាធិការលទ្ធកម្មនឹងមិនទទួលខុសត្រូវចំពោះការផ្ញើត្រឡប់ទៅវិញខុសទីកន្លែង និងការបើកមើលមុនឡើយ ។

## ១៤- សុពលភាពសំណើដេញថ្លៃ

សំណើដេញថ្លៃត្រូវមានសុពលភាពរយៈពេលយ៉ាងតិច៦០ (ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបើកសំណើដេញថ្លៃ។ សំណើដេញថ្លៃដែលមានសុពលភាពខ្លីជាងនេះ នឹងត្រូវបដិសេធ។

ក្នុងករណីចាំបាច់ គណៈកម្មាធិការលទ្ធកម្មអាចស្នើសុំឱ្យអ្នកដេញថ្លៃពន្យាររពេលសុពលភាពនៃសំណើដេញថ្លៃ តាមរយៈលិខិត ឬទូរសារដល់អ្នកដេញថ្លៃទាំងអស់។ អ្នកដេញថ្លៃអាចបដិសេធសំណើ ពន្យាររពេលនេះ ហើយអាចដកសំណើដេញថ្លៃវិញបាន ដោយមិនមានការខាតបង់ប្រាក់កក់ធានាការដេញថ្លៃ របស់ខ្លួនឡើយ។ ចំណែកអ្នកដេញថ្លៃដែលយល់ព្រមលើសំណើសុំពន្យាររពេលនេះ នឹងមិនអនុញ្ញាតឱ្យធ្វើការផ្លាស់ប្តូរសំណើដេញថ្លៃរបស់ខ្លួនឡើយ។

## ១៥- លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ

អ្នកដេញថ្លៃត្រូវកក់ប្រាក់ធានាការដេញថ្លៃដែលមានទឹកប្រាក់ចំនួន ៣ ០៨២ ៥០០៖០០ (បីលាន ប៉ែតសិបពីរពាន់ ប្រាំបួនរយរៀលគត់ ) ចូលក្នុងគណនីប្រាក់កក់របស់អគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានីខេត្ត បើកនៅធនាគារពាណិជ្ជណាមួយ ឬកក់នៅធនាគារពាណិជ្ជដៃគូណាមួយដែលបានចុះអនុស្សារណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមាន៖១.ធនាគារ អេស៊ីលីដា ភីអិលស៊ី ២.ធនាគារកាណាឌីយ៉ា ក.អ ៣.ធនាគារ ពាណិជ្ជកម្ម ក្រៅប្រទេសនៃកម្ពុជា ៤.ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី ៥.ធនាគារ វឌ្ឍនៈ(VattanacBank) ៦.ធនាគារ វឌ្ឍនៈអាស៊ីចំកាត់ (ABA) ៧.ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ៨.ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី ៩.ធនាគារ ជេត្រាស់ រ៉ូយ៉ាល់ និង១០.ធនាគារ ជីបម៉ុងខមមើសលប៊ែង ម.ក។

បន្ទាប់ពីបានកក់ប្រាក់រួច អ្នកដេញថ្លៃត្រូវស្នើសុំអគ្គនាយកដ្ឋានរតនាគារជាតិ ឬធនាគារពាណិជ្ជដៃគូចេញនូវលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ (មានទម្រង់ និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ) សម្រាប់ភ្ជាប់ជាមួយសំណើដេញថ្លៃរបស់ខ្លួន។ លិខិតធានាប្រាក់កក់ធានាការដេញថ្លៃនេះមានសុពលភាពរយៈពេលយ៉ាងតិច ៣០(សាមសិប)ថ្ងៃ ក្រោយសុពលភាពសំណើដេញថ្លៃ។ ក្នុងករណីមានការពន្យាររពេលសុពលភាពនៃសំណើដេញថ្លៃ សុពលភាពនៃប្រាក់កក់ធានាការដេញថ្លៃក៏ត្រូវពន្យាររពេលស្របគ្នាផងដែរ។

សំណើដេញថ្លៃណាដែលមិនបានភ្ជាប់មកជាមួយនូវលិខិតធានាប្រាក់កក់ខាងលើ ឬបំពេញប្រាក់កក់មិនបានត្រឹមត្រូវ ឬមិនគ្រប់ចំនួនទេនោះនឹងត្រូវបានចាត់ទុកជាមោឃៈ ឬមិនត្រូវបានជ្រើសរើស មកវាយតម្លៃ ប្រគល់កិច្ចសន្យាឡើយ។ ក្នុងរយៈពេល ៥ (ប្រាំ)ថ្ងៃ យ៉ាងយូរបន្ទាប់ពីអ្នកដេញថ្លៃឈ្នះ បានបង់ប្រាក់កក់ធានាអនុវត្តកិច្ចសន្យា និងបានចុះកិច្ចសន្យារួច ស្ថាប័នអនុវត្តលទ្ធកម្ម ឬអង្គភាពថវិកា ត្រូវចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការដេញថ្លៃ ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានីខេត្ត ឬ ធនាគារពាណិជ្ជដែលពាក់ព័ន្ធ ដើម្បីបង្វិលប្រាក់កក់ធានាការដេញថ្លៃជូនអ្នកដេញថ្លៃវិញ។

ប្រាក់កក់ធានាការដេញថ្លៃនេះនឹងត្រូវរឹបអូសបង់បង្វែរចូលគណនីកំពង់ផែស្វយ័តភ្នំពេញ ប្រសិនបើ៖

-អ្នកដេញថ្លៃដកសំណើរបស់ខ្លួនវិញក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ

-អ្នកដេញថ្លៃឈ្នះ មិនព្រមផ្តល់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

-អ្នកដេញថ្លៃឈ្នះមិនព្រមចុះកិច្ចសន្យាក្នុងរយៈពេលដែលបានកំណត់ក្នុងលិខិតស្តីពីការអញ្ជើញចុះកិច្ចសន្យា

## ១៦- ការកំណត់ពេលដាក់សំណើដេញថ្លៃ

-អ្នកដេញថ្លៃត្រូវដាក់សំណើដេញថ្លៃរបស់ខ្លួននៅអង្គភាពលទ្ធកម្មឱ្យបានមុនពេលវេលា និងកាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ។

-សំណើដេញថ្លៃណាមួយដែលដាក់ក្រោយពេលវេលា និងកាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃនោះ នឹងត្រូវបដិសេធ។

-ក្រោយពេលវេលា និងកាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ ការកែតម្រូវរាល់កំហុសឆ្គងក្នុងសំណើដេញថ្លៃមិនត្រូវបានអនុញ្ញាតឡើយ។

## ១៧- ការផ្លាស់ប្តូរ និងការដកសំណើដេញថ្លៃ

អ្នកដេញថ្លៃអាចផ្លាស់ប្តូរ ឬដកសំណើដេញថ្លៃរបស់ខ្លួនក្នុងរយៈពេល ៣ (បី)ថ្ងៃ មុនពេលផុត កំណត់កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ។ ការជូនដំណឹងរបស់អ្នកដេញថ្លៃពីការផ្លាស់ប្តូរ ឬដកសំណើដេញថ្លៃរបស់ខ្លួនត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយត្រូវបោះត្រាខាងខ្នងហើយបញ្ជូនទៅអង្គភាពលទ្ធកម្មដោយផ្ទាល់ ឬផ្ញើតាមទូរសារ ប៉ុន្តែត្រូវមានចុះហត្ថលេខាធានាអះអាង។ ការដកសំណើដេញថ្លៃក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃអាចបណ្តាលឱ្យមានការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ។ មិនអនុញ្ញាតឱ្យមានការកែប្រែសំណើដេញថ្លៃណាមួយបន្ទាប់ពីផុតកាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ។

## ១៨- ការបើកសំណើដេញថ្លៃ

រាល់សំណើដេញថ្លៃទាំងអស់ត្រូវបើកជាសាធារណៈភ្លាមៗ តាមពេលវេលា កាលបរិច្ឆេទ និងទីកន្លែងដូចបានកំណត់ក្នុងសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ ក្រោមការដឹកនាំរបស់ប្រធានគណៈកម្មាធិការលទ្ធកម្មដោយមានការចូលរួមពីគណៈកម្មាធិការលទ្ធកម្ម អ្នកដេញថ្លៃ និងអ្នកពាក់ព័ន្ធដទៃទៀត។ ព័ត៌មានសំខាន់ៗ ដូចជាឈ្មោះអ្នកដេញថ្លៃ ប្រាក់កក់ធានាការដេញថ្លៃ តម្លៃដាក់ដេញសរុប ការបញ្ចុះតម្លៃនានា ការកែប្រែ ឬការដកសំណើវិញ ត្រូវបានប្រកាស អាន បង្ហាញ និងកត់ត្រាឱ្យបានច្បាស់លាស់ នៅពេលបើកសំណើដេញថ្លៃ។ កំណត់ហេតុបើកសំណើដេញថ្លៃ ត្រូវបានចែកជូនគ្រប់អ្នកចូលរួមទាំងអស់។

ការបើកសំណើដេញថ្លៃនេះ ពុំមានន័យថាជាការប្រកាសលទ្ធផលឈ្នះ ចាញ់ឡើយ។ ការកំណត់ឈ្នះ ចាញ់ គឺអាស្រ័យទៅលើការវាយតម្លៃលើសំណើដេញថ្លៃនីមួយៗ។

## ១៩- ការវាយតម្លៃលើសំណើដេញថ្លៃ

ការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ និងប្រគល់កិច្ចសន្យា ធ្វើឡើងជាសម្ងាត់ និងដោយហ្មត់ចត់ស្រប តាមលក្ខខណ្ឌតម្រូវ និងលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងឯកសារដេញថ្លៃ និងផ្អែកលើព័ត៌មានសំខាន់ៗ ក្នុង កំណត់ហេតុស្តីពីការបើកសំណើដេញថ្លៃ។ ចាប់ពីពេលបើកសំណើដេញថ្លៃរហូតដល់ពេលសម្រេចប្រគល់ កិច្ចសន្យាជាផ្លូវការ ការទាក់ទងណាមួយរវាងអ្នកដេញថ្លៃ និងគណៈកម្មាធិការលទ្ធកម្មដែលពាក់ព័ន្ធនឹង សំណើដេញថ្លៃ មិនត្រូវបានអនុញ្ញាតឡើយ។

គណៈកម្មាធិការលទ្ធកម្មនឹងពិនិត្យមើលជាបឋមនូវសំណើដេញថ្លៃ ដោយកំណត់ថាតើមានកំហុស ក្នុងការគិតលេខនព្វន្តឬទេ? មានលិខិតធានាប្រាក់កក់ធានាដេញថ្លៃត្រឹមត្រូវឬទេ? មានចុះហត្ថ លេខាត្រឹមត្រូវ និងថាតើសំណើដេញថ្លៃជាទូទៅបានបំពេញតាមលក្ខខណ្ឌតម្រូវក្នុងឯកសារដេញថ្លៃឬទេ?

ក្នុងករណីដែលមានភាពមិនស្របគ្នារវាងចំនួនជាតួលេខ និងអក្សរនោះ ចំនួនដែលសរសេរជាអក្សរ ចាត់ទុកជាបានការ។

*<u>កំហុសលេខនព្វន្ត នឹងធ្វើការកែតម្រូវលើមូលដ្ឋានដូចខាងក្រោម៖</u>*

- ប្រសិនបើមានភាពមិនស្របគ្នារវាងតម្លៃសរុបដែលបានមកពីការគុណតម្លៃឯកតា និងបរិមាណ នោះ តម្លៃឯកតាត្រូវរក្សានៅដដែលដោយធ្វើការកែតម្រូវលើតម្លៃសរុប។
- ប្រសិនបើមានភាពមិនស្របគ្នារវាងតម្លៃដេញថ្លៃសរុប និងផលបូកតម្លៃសរុបនីមួយៗនោះ ផលបូកតម្លៃសរុបនីមួយៗត្រូវរក្សាទុកនៅដដែល ហើយធ្វើការកែតម្រូវលើតម្លៃដាក់ដេញថ្លៃ សរុប។
- ប្រសិនបើអ្នកដេញថ្លៃណាមិនព្រមទទួលយកនូវការកែតម្រូវទេ សំណើដេញថ្លៃរបស់ អ្នក ដេញថ្លៃនោះ នឹងត្រូវបដិសេធ។

មុនពេលវាយតម្លៃលម្អិត គណៈកម្មាធិការលទ្ធកម្មនឹងកំណត់ពីការឆ្លើយតបរបស់សំណើនីមួយៗ ទៅ នឹងឯកសារដេញថ្លៃ។ សំណើដេញថ្លៃដែលត្រូវបានចាត់ទុកថាបានឆ្លើយតបពេញលេញ គឺជាសំណើ ដែល ឆ្លើយតបគ្រប់លក្ខខណ្ឌដែលមានចែងនៅក្នុងឯកសារដេញថ្លៃ។ គណៈកម្មាធិការលទ្ធកម្មនឹងពិចារណាបដិ សេធនូវសំណើដេញថ្លៃណាដែលឆ្លើយតបមិនសមស្រប។ គណៈកម្មាធិការលទ្ធកម្មត្រូវធ្វើការប្រៀបធៀប សំណើដេញថ្លៃ ដែលត្រូវបានកំណត់ថាជាសំណើដេញថ្លៃមានការឆ្លើយតបតាម លក្ខខណ្ឌតម្រូវ ដើម្បីធ្វើ ចំណាត់ថ្នាក់អ្នកដេញថ្លៃនាំមុខ។

## ២០- ការត្រួតពិនិត្យលក្ខណសម្បត្តិតាមក្រោយ

មុនសម្រេចប្រគល់កិច្ចសន្យាគណៈកម្មាធិការលទ្ធកម្ម នឹងធ្វើការត្រួតពិនិត្យលក្ខណសម្បត្តិតាម ក្រោយរបស់អ្នកដេញថ្លៃនាំមុខទី១ ដោយធ្វើការផ្ទៀងផ្ទាត់ឡើងវិញលើឯកសារភស្តុតាងនានាដើម្បីធានា ភាពត្រឹមត្រូវ នៃតម្រូវការផ្លូវច្បាប់ តម្រូវការសមត្ថភាពហិរញ្ញវត្ថុ បច្ចេកទេស បទពិសោធន៍ ជាមួយ នឹងស្ថានភាពជាក់ស្តែងរបស់អ្នកដេញថ្លៃនាំមុខដើម្បីធានាការអនុវត្តកិច្ចសន្យា។ ប្រសិនបើអ្នកដេញថ្លៃនាំ មុខទី១ មិនមានលក្ខណសម្បត្តិគ្រប់គ្រាន់ គណៈកម្មាធិការលទ្ធកម្មនឹងបដិសេធសំណើដេញថ្លៃនោះ ហើយ បន្តធ្វើការត្រួតពិនិត្យលក្ខណសម្បត្តិតាមក្រោយរបស់អ្នកដេញថ្លៃនាំមុខបន្ទាប់ទៀត។

## ២១- លក្ខណៈវិនិច្ឆ័យនៃការសម្រេចប្រគល់កិច្ចសន្យា

គណៈកម្មាធិការលទ្ធកម្ម នឹងសម្រេចប្រគល់កិច្ចសន្យាទៅឱ្យអ្នកដេញថ្លៃឈ្នះដែលសំណើរបស់អ្នកដេញថ្លៃនោះត្រូវបានវាយតម្លៃថាឆ្លើយតបសមស្រប និងមានតម្លៃទាបជាងគេហើយត្រូវបានកំណត់ថាមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការអនុវត្តកិច្ចសន្យា។

## ២២- សេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា

បន្ទាប់ពីបញ្ចប់ការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ គណៈកម្មាធិការលទ្ធកម្ម នឹងចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាទៅឱ្យអ្នកដេញថ្លៃឈ្នះ ដោយចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់។

## ២៣- ការចុះហត្ថលេខាលើកិច្ចសន្យា

បន្ទាប់ពីរយៈពេល ១០ (ដប់)ថ្ងៃ នៃថ្ងៃធ្វើការ នៃការចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា ប្រសិនបើពុំមានការជំទាស់តវ៉ាណាមួយ ឬបន្ទាប់ពីការជំទាស់តវ៉ាទាំងអស់ត្រូវបានដោះស្រាយ គណៈកម្មាធិការលទ្ធកម្មធ្វើការអញ្ជើញអ្នកដេញថ្លៃឈ្នះមកចុះហត្ថលេខាលើកិច្ចសន្យា ដោយភ្ជាប់ជាមួយនូវលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ)ថ្ងៃ។ ក្នុងករណីដែលអ្នកដេញថ្លៃឈ្នះ មិនព្រមចុះហត្ថលេខាលើកិច្ចសន្យា ឬពន្យាររពេលចុះហត្ថលេខាលើកិច្ចសន្យាដោយពុំមានមូលហេតុសមស្របនោះប្រាក់កក់ធានាការដេញថ្លៃត្រូវបានរឹបអូសបង់ចូលថវិកាគណនីកំពង់ផែស្វយ័តភ្នំពេញ ហើយអ្នកដេញថ្លៃនោះត្រូវបានកំណត់ថាជាមុខសញ្ញាសម្រាប់ការចុះឈ្មោះក្នុងបញ្ជីខ្មៅ។ ជាមួយគ្នានេះគណៈកម្មាធិការលទ្ធកម្មនឹងពិនិត្យនិងវាយតម្លៃលក្ខណសម្បត្តិតាមក្រោយរបស់អ្នកដេញថ្លៃនាំមុខបន្ទាប់។

## ២៤- បណ្តឹងតវ៉ា

បណ្តឹងតវ៉ាអាចត្រូវបានធ្វើឡើងនៅគ្រប់ដំណាក់កាល នៃដំណើរការកិច្ចលទ្ធកម្មមុនពេលចុះកិច្ចសន្យា។ បណ្តឹងតវ៉ាដែលបានធ្វើឡើងក្នុងរយៈពេលនៃការវាយតម្លៃសំណើដេញថ្លៃ នឹងមិនត្រូវបានឆ្លើយតបឡើយ។ ការឆ្លើយតប នោះ នឹងត្រូវបានធ្វើឡើងបន្ទាប់ពីការវាយតម្លៃបានបញ្ចប់។

បណ្តឹងតវ៉ាត្រូវផ្ញើជូនគណៈកម្មាធិការលទ្ធកម្មដូចមានឈ្មោះ និងអាសយដ្ឋានក្នុងឯកសារដេញថ្លៃ។ គណៈកម្មាធិការលទ្ធកម្មធ្វើអង្កេតលើមូលដ្ឋាន នៃបណ្តឹងតវ៉ា និងធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលបណ្តឹងតវ៉ានោះ លើកលែងតែក្នុងករណី ការតវ៉ាទាំងឡាយដែលបានទទួលក្នុងកំឡុងពេលវាយតម្លៃ។

ក្នុងករណីការឆ្លើយតបរបស់គណៈកម្មាធិការលទ្ធកម្ម មិនបំពេញតាមបំណងអ្នកដេញថ្លៃចាញ់ ឬក៏ពុំមានការឆ្លើយតបណាមួយត្រូវបានធ្វើឡើងនោះ បណ្តឹងតវ៉ា នឹងត្រូវបានបញ្ជូនទៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ធ្វើការឆ្លើយតប ក្នុងរយៈពេល១៥ (ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ។ ករណីនេះ មិនបណ្តាលឱ្យមានការបាត់បង់សិទ្ធរបស់អ្នកដេញថ្លៃចំពោះបណ្តឹងតវ៉ាបន្តណាមួយផ្សេងទៀតដែលអ្នកដេញថ្លៃអាចជ្រើសរើសនោះទេ។

## ២៥- ការចុះហត្ថលេខាលើកិច្ចសន្យា

បន្ទាប់ពីរយៈពេល១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ នៃការចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា ប្រសិនបើពុំមានការជំទាស់តវ៉ាណាមួយ ឬបន្ទាប់ពីការជំទាស់តវ៉ាទាំងអស់ត្រូវបានដោះស្រាយ គណៈកម្មាធិការលទ្ធកម្មធ្វើការអញ្ជើញអ្នកដេញថ្លៃឈ្នះមកចុះហត្ថលេខា លើកិច្ចសន្យាដោយភ្ជាប់ជាមួយនូវ

លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ក្នុងរយៈពេលយ៉ាងយូរ៧ (ប្រាំពីរ)ថ្ងៃ ។ ក្នុងករណីដែលអ្នកដេញថ្លៃឈ្នះមិនព្រមចុះហត្ថលេខាលើកិច្ចសន្យា ឬពន្យារពេលចុះហត្ថលេខាលើកិច្ចសន្យា ដោយពុំមានមូលហេតុសមស្របនោះ ប្រាក់កក់ធានាការដេញថ្លៃត្រូវបានរឹបអូសថវិកាបង់ចូលគណនីកំពង់ផែស្វយ័តភ្នំពេញ ហើយអ្នកដេញថ្លៃនោះ ត្រូវបានកំណត់ថាជាមុខសញ្ញាសម្រាប់ការចុះឈ្មោះក្នុងបញ្ជីខ្មៅ។

ជាមួយគ្នានេះគណៈកម្មាធិការលទ្ធកម្មពិនិត្យ និងវាយតម្លៃ លក្ខណសម្បត្តិតាមក្រោយរបស់អ្នកដេញថ្លៃនាំមុខបន្ទាប់។

## ២៦- ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃយ៉ាងយូរបន្ទាប់ពីទទួលបានលិខិតស្តីពីការអញ្ជើញចុះកិច្ចសន្យា អ្នកដេញថ្លៃឈ្នះត្រូវផ្តល់លិខិតធានាការអនុវត្តកិច្ចសន្យាជូនស្ថាប័នអនុវត្តលទ្ធកម្មដើម្បីដំណើរការចុះកិច្ចន្យា។

ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាមានទឹកប្រាក់ស្មើនឹង ១០ (ដប់) ភាគរយ នៃតម្លៃកិច្ចសន្យាអ្នកដេញថ្លៃឈ្នះត្រូវកក់ចូលក្នុងគណនីប្រាកកក់របស់អគ្គនាយកដ្ឋានរតនាគារជាតិ ឬ រតនាគាររាជធានី ខេត្ត បើកនៅធនាគារពាណិជ្ជណាមួយ ឬ កក់នៅធនាគារពាណិជ្ជដៃគូណាមួយ ដែលបានចុះអនុស្សារណៈនៃការឃោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមមានៈ ១.ធនាគារ អេស៊ីលីដា ភីអិលស៊ី ២.ធនាគារ កាណាឌីយ៉ា ក.អ ៣.ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ៤.ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី ៥.ធនាគារ វឌ្ឍនៈ (Vattanac Bank) ៦.ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ (ABA) ៧.ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី៨.ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី ៩.ធនាគារ ជេត្រាស់ រ៉ូយ៉ាល់ និង១០. ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក។

បន្ទាប់ពីបានកក់ប្រាក់រួច អ្នកដេញថ្លៃឈ្នះត្រូវស្នើសុំអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ឬ ធនាគារពាណិជ្ជដៃគូ ចេញនូវលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា (មានទម្រង់ និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ) រួចប្រគល់ជូន "អង្គភាពលទ្ធកម្ម នៃកំពង់ផែស្វយ័តភ្នំពេញ" មុនពេលចុះកិច្ចសន្យា។

ការខកខានក្នុងការកក់ប្រាក់ជានាការអនុវត្តកិច្ចសន្យា គឺជាមូលដ្ឋានគ្រប់គ្រាន់ក្នុងការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ។

ក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ បន្ទាប់ពីការប្រគល់ទទួលទំនិញ គ្រប់ចំនួន ឬបន្ទាប់ពីផុតរយៈពេលធានាគុណភាពទំនិញ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាទៅ អគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារជាតិរាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូពាក់ព័ន្ធ ដើម្បីបង្វិលប្រាក់កក់ ជូនអ្នកផ្គត់ផ្គង់វិញ។

ក្នុងករណី "អ្នកទទួលការ" មិនបានអនុវត្តតាមប្រការណាមួយនៃកិច្ចសន្យា ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យានេះនឹងត្រូវរឹបអូសបង់ចូលថវិកាគណនីកំពង់ផែស្វយ័តភ្នំពេញ ហើយនឹងត្រូវបានកំណត់ថាជាមុខសញ្ញាសម្រាប់ការចុះឈ្មោះក្នុងបញ្ជីខ្មៅ។

# លក្ខខណ្ឌនៃកិច្ចសន្យា

## ១-និយមន័យ

-កំពង់ផែស្វយ័តភ្នំពេញហៅថាភាគី "អ្នកម្ចាស់ការ" តំណាងដោយ...........................................មុខងារ ........................មានអាសយដ្ឋាន..........................................................................................................។

-ក្រុមហ៊ុន/សហគ្រាស.............................................................ដែលបានចូលរួមដេញថ្លៃហើយត្រូវបានជ្រើសរើសប្រគល់កិច្ចសន្យាការងារគូស គំនូសផ្លូវ RTG គំនូសលេខ Row& Bay គំនូសទីតាំងដាក់កុងតឺន័រ នៅលើទីលាន ជំហានទី១ ជំហានទី២ ស្ថិតនៅចំណតផែកុងតឺន័រ LM១៧ ហៅថាភាគី"អ្នកទទួលការ"តំណាងដោយ..................................មុខងារ.........................................................អាសយដ្ឋាន........ ..........................................................................................លេខទូរស័ព្ទ........................................................ .......អ៊ីមែល..................................................។

-ការងារគូស គំនូសផ្លូវ RTG គំនូសលេខ Row& Bay គំនូសទីតាំងដាក់កុងតឺន័រ នៅលើទីលាន ជំហានទី១ ជំហានទី២ ស្ថិតនៅចំណតផែកុងតឺន័រ LM១៧ដែលអនុវត្តដោយភាគី "អ្នកទទួលការ" ហៅកាត់ថា "ការងារ"។

-តម្លៃសរុបនៃ "ការងារ" ដែលចុះកិច្ចសន្យាហៅថា "តម្លៃកិច្ចសន្យា"។

## ២- ភារកិច្ចរបស់ "អ្នកម្ចាស់ការ"

"អ្នកម្ចាស់ការ" ត្រូវទទួលខុសត្រូវលើការទូទាត់តម្លៃកិច្ចសន្យាជូន "អ្នកទទួលការ" តាមលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យា បន្ទាប់ពីបានទទួលកំណត់ហេតុវាយតម្លៃលទ្ធផល "ការងារ" របស់ "អ្នកម្ចាស់ការ" ត្រូវចាត់តាំងក្រុមការងារបច្ចេកទេសចុះត្រួតពិនិត្យលក្ខណៈបច្ចេកទេសជាមុនរួចធ្វើរបាយការណ៍ជូនគណៈកម្មការវាយតម្លៃ និងប្រគល់-ទទួល។

## ៣- ភារកិច្ចរបស់ "អ្នកទទួលការ"

"អ្នកទទួលការ" ត្រូវចាប់ផ្តើមអនុវត្ត "ការងារ" ក្នុងរយៈពេល៧ (ប្រាំពីរ)ថ្ងៃ យ៉ាងយូរ ក្រោយពីកិច្ចសន្យាចូលជាធរមាន។ "អ្នកទទួលការ" ត្រូវអនុវត្ត "ការងារ" ដោយអនុលោមតាមលក្ខណៈបច្ចេកទេស គំនូសប្លង់ និងប្រតិទិនការងារដែលមានចែងនៅក្នុងកិច្ចសន្យា។ ប្រតិទិនការងារត្រូវផ្អែកលើការអនុវត្តចំនួនថ្ងៃ ដោយមិនគិតថ្ងៃឈប់សម្រាកធម្មតាលើកលែងតែថ្ងៃឈប់សម្រាកទាំងឡាយណាដែលកំណត់ដោយច្បាប់។ "អ្នកទទួលការ" ត្រូវទទួលខុសត្រូវចំពោះរាល់ការខូចខាត ឬបាត់បង់សម្ភារ និងអគ្គិភ័យ ការរងរបួស ឬគ្រោះថ្នាក់ដល់អាយុជីវិតចំពោះបុគ្គលណាមួយ ក្នុងពេលអនុវត្តកិច្ចសន្យា។ "អ្នកទទួលការ" ត្រូវទទួលខុសត្រូវផងដែរចំពោះសុវត្ថិភាពការងារនៅក្នុងការដ្ឋាន។

## ៤- ទឹកដៃ និងសម្ភារ

រាល់ "ការងារ" ត្រូវប្រើទឹកដៃ និងសម្ភារដែលមានគុណភាពល្អ ហើយជាប្រភេទសមរម្យសម្រាប់ការងារធ្វើដោយដៃ ឬដោយគ្រឿងចក្រ ហើយត្រូវស្របតាមការលម្អិតក្នុងលក្ខណៈបច្ចេកទេស។ ចំពោះសម្ភារដែលយកមកប្រើត្រូវមានការពិសោធន៍គុណភាព និងមានការឯកភាពពី "អ្នកម្ចាស់ការ" ជាមុនទើបអាចប្រើប្រាស់បានដោយឡែកចំពោះឧបករណ៍ដែលយកមកប្រើប្រាស់ក្នុងការអនុវត្ត "ការងារ" "អ្នកទទួលការ" ត្រូវទទួលខុសត្រូវក្នុងការទិញ ឬជួលយកមកប្រើប្រាស់ក្នុងការដ្ឋាន។

## ៥- ការការពារអគ្គិភ័យ

"អ្នកទទួលការ" ត្រូវទទួលខុសត្រូវចំពោះការការពារអគ្គិភ័យនៅក្នុងការដ្ឋាន ដែលកំពុងអនុវត្តការងារ។ ឧបករណ៍៖ ពន្លត់អគ្គិភ័យ ត្រូវមានជាប្រចាំនៅក្នុងការដ្ឋាន "ការងារ" និងក្រោមការត្រួតពិនិត្យរបស់ "អ្នកទទួលការ" ក្នុងរយៈពេលអនុវត្ត "ការងារ"។ "អ្នកទទួលការ" ត្រូវអនុវត្តដោយប្រុងប្រយ័ត្នចំពោះការប្រើប្រាស់ឧបករណ៍ ឬប្រតិបត្តិការដែលអាចបណ្តាលឱ្យឆាបឆេះដោយប្រការណាមួយ។

"អ្នកទទួលការ" ត្រូវធានាថាកម្មកររបស់ខ្លួនទាំងអស់ចេះប្រើឧបករណ៍ពន្លត់អគ្គិភ័យ ដែលត្រូវបានប្រគល់ឱ្យប្រើប្រាស់នៅក្នុងការដ្ឋានពេលមានអគ្គិភ័យ។

## ៦- ការការពារបរិស្ថាន

"អ្នកទទួលការ" ត្រូវធានាលើការខូចខាតតិចតួច ឬច្រើនដែលបណ្តាលឱ្យប៉ះពាល់ដល់បរិស្ថាន រុក្ខជាតិ រចនាសម្ព័ន្ធមានស្រាប់ និងផលប្រយោជន៍ផ្សេងៗ។ រាល់ការចំណាយលើការជួសជុល/សាងសង់ឡើងវិញ និងការសងជម្ងឺចិត្ត ជាបន្ទុករបស់ "អ្នកទទួលការ"។

## ៧- ការចុះកិច្ចសន្យាបន្ត

ការចុះកិច្ចសន្យាបន្ត នៃកិច្ចសន្យាទាំងមូលមិនត្រូវបានអនុញ្ញាតជាដាច់ខាត ។ "អ្នកទទួលការ" អាចចុះកិច្ចសន្យាបន្តឱ្យ "អ្នកទទួលការសំណង់បន្ត" ដើម្បីឱ្យអនុវត្តផ្នែកណាមួយនៃកិច្ចសន្យាបាន ដរាបណាមានការយល់ព្រមពី "អ្នកម្ចាស់ការ"។ "អ្នកទទួលការសំណង់បន្ត" ត្រូវចុះកិច្ចសន្យាជាមួយ "អ្នកទទួលការសំណង់ដើម" មិនមែនចុះកិច្ចសន្យាជាមួយ "អ្នកម្ចាស់ការ" នោះទេ។ ប្រសិនបើ "អ្នកទទួល ការសំណង់បន្ត" មានកំហុសឆ្គងណាមួយ "អ្នកទទួលការសំណង់ដើម" ត្រូវទទួលខុសត្រូវទាំងស្រុង ដោយធានាថាកំហុសទាំងនោះត្រូវបានកែតម្រូវ។ "អ្នកម្ចាស់ការ" មិនធ្វើការដោះស្រាយបញ្ហាណាមួយដោយផ្ទាល់ជាមួយ "អ្នកទទួលការសំណង់បន្ត" ឡើយ។

"អ្នកទទួលការសំណង់ដើម" អាចចុះកិច្ចសន្យាបន្តទៅ "អ្នកទទួលការសំណង់បន្ត" នូវផ្នែកណាមួយនៃកិច្ចសន្យាដែលមានតម្លៃយ៉ាងច្រើនបំផុត៤០ (សែសិប)ភាគរយ នៃតម្លៃកិច្ចសន្យា ដោយមានការយល់ព្រមពី "អ្នកម្ចាស់ការ" ជាមុន។ "អ្នកទទួលការសំណង់បន្ត" នោះត្រូវតែជាអ្នកទទួលការសំណង់ដែលស្ថិតនៅក្នុងបញ្ជីឈ្មោះអ្នកទទួលការសំណង់ ប្រភេទសមស្របទៅនឹងការងារចុះកិច្ចសន្យានោះ។

## ៨- ឃ្លាំងស្តុកសម្ភារ និងជម្រកស្នាក់នៅរបស់កម្មករ

"អ្នកទទួលការ" ត្រូវទទួលខុសត្រូវចំពោះឃ្លាំងស្តុកសម្ភារ និងត្រូវការពារនូវសម្ភារបរិក្ខារសម្រាប់ "ការងារ"ទាំងអស់នៅការដ្ឋានសម្រាប់រយៈពេលនៃការអនុវត្តកិច្ចសន្យា។ "អ្នកទទួលការ" ត្រូវទទួលខុសត្រូវដោយខ្លួនឯង រាល់ការបាក់បែក ឬការបាត់បង់សម្ភារ។ "អ្នកទទួលការ" ត្រូវសង់ជម្រកស្នាក់នៅសម្រាប់កម្មករឱ្យបានសមស្របតាមចំនួនកម្មកររបស់ខ្លួន។

## ៩- ការគោរពបទដ្ឋានបច្ចេកទេសសំណង់

"អ្នកទទួលការ" ត្រូវទទួលខុសត្រូវចំពោះការគោរពបទដ្ឋានបច្ចេកទេស ទម្រង់ រចនាបថនៃសំណង់ និងត្រូវធានាចំពោះភាពត្រឹមត្រូវនៃទីតាំងសំណង់ និងភាពត្រឹមត្រូវនៃសំណង់ រួមមានកម្រិត កម្ពស់ ទំហំ ខ្នាត...ជាដើម។ ក្នុងរយៈពេលសាងសង់/ជួសជុល "អ្នកទទួលការ" ត្រូវកែតម្រូវរាល់កំហុសទាំងឡាយឱ្យបានសមស្រប មុននឹងធ្វើការប្រគល់ទទួលសំណង់។

## ១០- ការបញ្ជាកែប្រែ

ក្នុងរយៈពេលអនុវត្ត "ការងារ" "អ្នកម្ចាស់ការ" អាចធ្វើការកែប្រែគុណភាព ឬបរិមាណនៃការងារ។ ការកែប្រែនេះ អាចមាន ៖

- ការបង្កើន ឬបន្ថយបរិមាណការងារដែលមានចែងក្នុងកិច្ចសន្យា
- ការដកចេញ ឬការដាក់បញ្ចូលនូវសម្ភារអ្វីមួយទៅក្នុង "ការងារ"
- ការកែប្រែ ទំហំ ខ្នាតនៃផ្នែកណាមួយនៃ "ការងារ"
- ការកែប្រែរចនាបថ ឬប្រភេទនៃការងារណាមួយ
- ការសាងសង់បន្ថែមណាមួយ
- ការកែប្រែនូវលំដាប់ ឬរយៈពេលនៃសកម្មភាព"ការងារ "

ប្រសិនបើភាគី "អ្នកទទួលការ" ទទួលយកនូវការផ្លាស់ប្តូរនេះ តាមលក្ខខណ្ឌដែលបានព្រមព្រៀងគ្នាឯកសារកែប្រែនឹងក្លាយជាឯកសារឧបសម្ព័ន្ធបន្ថែមនៃកិច្ចសន្យា ដោយរក្សាតម្លៃកិច្ចសន្យានៅដដែល។

*ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការកែប្រែនោះត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។*

## ១១- ការពន្យាររពេលបញ្ចប់ "ការងារ"

"អ្នកទទួលការ" អាចស្នើសុំពន្យាររពេលបញ្ចប់ "ការងារ" បានដោយមានការយល់ព្រមពី "អ្នកម្ចាស់ការ" ផ្អែកលើមូលហេតុជាក់ស្តែង។ "អ្នកទទួលការ" ត្រូវជូនដំណឹងពីរាល់ព្រឹត្តិការណ៍ដែលបណ្តាលឱ្យមានការយឺតយ៉ាវ ហើយ "អ្នកម្ចាស់ការ" នឹងពិនិត្យ និងសម្រេចលើការសុំពន្យាររពេលបញ្ចប់ការងារមិនឱ្យលើសពី៧ (ប្រាំពីរ)ថ្ងៃ បន្ទាប់ពីបានទទួលលិខិតស្នើសុំរបស់ "អ្នកទទួលការ"។ ប្រសិនបើ "អ្នកទទួលការ" ខកខានក្នុងការប្រកាសជូនដំណឹងជាមុនអំពីការយឺតយ៉ាវ ឬខកខានក្នុងការធ្វើកិច្ចសហការ ដើម្បីដោះស្រាយការយឺតយ៉ាវនោះ ការយឺតយ៉ាវបែបនេះ មិនត្រូវបានពិចារណាដើម្បីផ្តល់ការពន្យាររពេលបន្ថែមឡើយ។

*ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ការពន្យាររពេលនោះ ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។*

## ១២- ការធ្វើតេស្តសាកល្បង

"អ្នកម្ចាស់ការ" ត្រូវធ្វើការផ្ទៀងផ្ទាត់ការងាររបស់ "អ្នកទទួលការ" និងជូនដំណឹងទៅ "អ្នកម្ចាស់ការ" ត្រូវធ្វើការផ្ទៀងផ្ទាត់ការងាររបស់ "អ្នកទទួលការ" និងជូនដំណឹងទៅ "អ្នកទទួលការ" អំពីវិកលភាពនានាដែលបានរកឃើញ។ ការផ្ទៀងផ្ទាត់នេះ មិនត្រូវធ្វើឱ្យប៉ះពាល់ដល់ការទទួលខុសត្រូវរបស់ "អ្នកទទួលការ" ឡើយ។ "អ្នកម្ចាស់ការ" អាចណែនាំដល់ "អ្នកទទួលការ" ឱ្យធ្វើតេស្តសាកល្បងការងារណាមួយដែល "អ្នកម្ចាស់ការ" យល់ឃើញថាមានវិកលភាព។

"អ្នកម្ចាស់ការ" អាចស្នើឱ្យ "អ្នកទទួលការ" ធ្វើតេស្តសាកល្បងលើការងារដែលមិនមានបញ្ជាក់នៅក្នុងលម្អិតលក្ខណៈបច្ចេកទេស ដើម្បីផ្ទៀងផ្ទាត់រកវិកលភាព។ ប្រសិនបើការធ្វើតេស្តបង្ហាញថាមានវិកល ភាពនោះ "អ្នកទទួលការ" ត្រូវទទួលរ៉ាប់រងក្នុងការទូទាត់សម្រាប់ការធ្វើតេស្ត និងសម្រាប់ការសាងសង់/ជួសជុលឡើងវិញ។ ប្រសិនបើពុំមានវិកលភាពទេនោះ សោហ៊ុយចំណាយសម្រាប់ការធ្វើតេស្ត ជាបន្ទុករបស់ "អ្នកម្ចាស់ការ"។

**១៣- ការសម្អាតការដ្ឋាន**

"អ្នកទទួលការ" ត្រូវរក្សាភាពស្អាតជានិច្ចនៅការដ្ឋាន ហើយត្រូវប្រមូលចោលនូវសំរាម ឬរបស់របរផ្សេងៗ ដែលបានគរទុកពេលបញ្ចប់"ការងារ"។ "អ្នកទទួលការ" ត្រូវសំអាតការដ្ឋានឱ្យបានស្អាតល្អ មុននឹងប្រគល់ទៅឱ្យ "អ្នកម្ចាស់ការ"

**១៤- ការបញ្ចប់ការងារ**

"ការងារ" ក្នុងកិច្ចសន្យាដែលត្រូវបានចាត់ទុកថាអនុវត្តចប់ គឺនៅពេលដែលការងារទាំងអស់ត្រូវបានបញ្ចប់ដោយត្រឹមត្រូវ និងឆ្លងកាត់ការត្រួតពិនិត្យចុងក្រោយពីគណៈកម្មការវាយតម្លៃ និងប្រគល់ ទទួលសំណង់។ នៅពេលបញ្ចប់ "ការងារ" "អ្នកទទួលការ" ត្រូវស្នើសុំ "អ្នកម្ចាស់ការ" នូវលិខិតបញ្ជាក់ពីការបញ្ចប់ការងារ។ "អ្នកម្ចាស់ការ" នឹងចេញលិខិតបញ្ជាក់ពីការបញ្ចប់ការងារ នៅក្នុងរយៈពេលដប់បួន (១៤) ថ្ងៃ បន្ទាប់ពីបានទទួលសំណើពី "អ្នកទទួលការ" ដោយបញ្ជាក់អំពីកាលបរិច្ឆេទត្រឹមត្រូវ ឬអំពីការងារដែលនៅសល់ត្រូវបំពេញបញ្ចប់។

**១៥- ការធានាគុណភាពសំណង់**

"អ្នកទទួលការ" ត្រូវធានាគុណភាពសំណង់ក្នុងរយៈពេល១២ (ដប់ពីរ)ខែ គិតចាប់ពីកាលបរិច្ឆេទនៃលិខិតបញ្ជាក់ពីការបញ្ចប់ "ការងារ" ។ ក្នុងរយៈពេលធានាគុណភាពសំណង់នេះ ក្នុងករណីពិនិត្យឃើញកន្លែងណាដែលមានលក្ខណៈមិនប្រក្រតី បណ្តាលមកពីខ្វះលក្ខណៈបច្ចេកទេស ដូចជា ជ្រាបទឹក ប្រេះស្រាំ បែកបាក់ ការស្រុត ឬដួលរលំ.......។ល។ នោះ "អ្នកម្ចាស់ការ" នឹងធ្វើលិខិតអញ្ជើញ "អ្នកទទួលការ" មកពិភាក្សាដើម្បីធ្វើការសាងសង់/ជួសជុលសំណង់ឡើងវិញ។ ការចំណាយលើការសាងសង់/ជួសជុលខាងលើជាបន្ទុករបស់ "អ្នកទទួលការ"ទាំងស្រុង។ ប្រសិនបើក្នុងរយៈពេល៧ (ប្រាំពីរ)ថ្ងៃ បន្ទាប់ពី "អ្នកម្ចាស់ការ" ធ្វើលិខិតស្នើទៅ "អ្នកទទួលការ" ឱ្យមកសាងសង់/ជួសជុលសំណង់ ហើយ "អ្នកទទួលការ" ពុំបានមកសាងសង់/ជួសជុលសំណង់ឡើងវិញនោះ "អ្នកម្ចាស់ការ" មានសិទ្ធិប្រគល់ការងារនេះ ឱ្យទៅអ្នកផ្សេងទៀតធ្វើជំនួស រីឯប្រាក់ទូទាត់ការងារនេះ "អ្នកម្ចាស់ការ" នឹងដកចេញពីប្រាក់តម្កល់ធានាការអនុវត្តកិច្ចសន្យា។

ករណី ពិនិត្យឃើញថាមានការជ្រាបទឹក ប្រេះស្រាំ បែកបាក់ ការស្រុត ឬដួលរលំ....... បណ្តាលមកពីប្រធានស័ក្តិនោះរាល់ការចំណាយលើការងារសាងសង់/ជួសជុលសំណង់ឡើងវិញជាបន្ទុករបស់ "អ្នកម្ចាស់ការ"។

ការបញ្ចប់សុពលភាពធានាគុណភាពសំណង់ជាស្ថាពរ ត្រូវមានកំណត់ហេតុបញ្ជាក់ពីគណៈកម្មការប្រគល់ ទទួលសំណង់ច្បាស់លាស់ ដោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

**១៦- ការចុះបញ្ជីចំណាយ និងរបាយការណ៍**

"អ្នកទទួលការ" ត្រូវចុះបញ្ជីនូវវិក្កយប័ត្រទិញទំនិញ ឬចំណាយផ្សេងៗដែលបានប្រើ ឬក៏ដើម្បី អនុវត្តបញ្ចប់ការងារក្នុងកិច្ចសន្យា ហើយការចំណាយនោះ ត្រូវចុះបញ្ជីឱ្យបានត្រឹមត្រូវ សម្រាប់រាយការណ៍ ជូនភាគី "អ្នកម្ចាស់ការ" និងរក្សាទុកសម្រាប់អ្នកត្រួតពិនិត្យ ប្រសិនបើចាំបាច់នៅពេលណាមួយក្នុងអំឡុងពេលអនុវត្តកិច្ចសន្យា។

**១៧-ការត្រួតពិនិត្យការដ្ឋាន**

ក្នុងអំឡុងពេលនៃការអនុវត្តកិច្ចសន្យា "អ្នកទទួលការ" ត្រូវអនុញ្ញាតឱ្យ"អ្នកម្ចាស់ការ" ចូលការដ្ឋានដើម្បីពិនិត្យលើការងារដែលកំពុងអនុវត្ត។

**១៨- ការបញ្ចប់កិច្ចសន្យា**

"អ្នកម្ចាស់ការ" អាចពិនិត្យពិចារណាបញ្ចប់កិច្ចសន្យាក្រោយរយៈពេល១៥ (ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីបានជូនដំណឹងទៅឱ្យ "អ្នកទទួលការ" ដោយមូលហេតុដូចតទៅ ៖

- ការបន្តការងារទៅទៀត គឺមិនអាចធ្វើទៅបាន ឬបណ្តាលឱ្យខូចប្រយោជន៍ "អ្នកម្ចាស់ការ"។
- "អ្នកទទួលការ" ស្ថិតក្នុងស្ថានភាពដែលមិនអាចសងបំណុលគេបាន ឬក៏គ្មានមធ្យោបាយហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីបញ្ចប់ការងារ។
- "អ្នកទទួលការ" បានរំលោភលើលក្ខខណ្ឌមួយចំនួននៃកិច្ចសន្យា ហើយមិនអាចចាត់វិធានការកែតម្រូវលើកំហុសទាំងនោះ។
- "អ្នកទទួលការ" មិនមានលទ្ធភាពធ្វើការសាងសង់/ជួសជុលតាមពេលវេលាដែលចែងក្នុងកិច្ចសន្យា។
- "អ្នកទទួលការ" មិនអាចសងការខូចខាតនៅក្នុងលក្ខខណ្ឌណាមួយខាងលើក្នុងអំឡុងពេល១០ (ដប់)ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងពីកំហុសដែលបានបញ្ជាក់ពីប្រភេទនៃកំហុស។

*ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការបញ្ចប់កិច្ចសន្យានេះត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។*

## ១៩- ករណីប្រធានសក្តិ

"ប្រធានសក្តិ" គឺជាព្រឹត្តិការណ៍ដែលមិនអាចគិតទុកមុនបាន ឬមិនអាចជៀសវាងបាន ហើយដែលមូលហេតុរបស់វា មិនបណ្តាលមកពីការធ្វេសប្រហែស ឬខ្វះការប្រុងប្រយ័ត្ន ដោយភាគី "អ្នកទទួលការ"។ ព្រឹត្តិការណ៍ទាំងនេះ មានដូចជា សង្គ្រាម ការបះបោរ អគ្គិភ័យ ទឹកជំនន់ ជម្ងឺរាតត្បាត ការដាក់កម្រិតឱ្យនៅដាច់ពីគេ ឬការហ៊ុមព័ទ្ធការដឹកជញ្ជូន។ល។

ការយឺតយ៉ាវឬការខកខានក្នុងការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា ដែលបណ្តាលពីករណីប្រធានសក្តិ នេះ "អ្នកទទួលការ" មិនត្រូវបានទទួលរងនូវការផាកពិន័យ ឬរឹបអូសប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាឡើយ។

## ២០- ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

"អ្នកទទួលការ" ត្រូវកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាដែលមានទឹកប្រាក់ស្មើនឹង១០ (ដប់)ភាគរយនៃតម្លៃកិច្ចសន្យាសរុបចូលទៅក្នុងគណនីប្រាក់កក់របស់អគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី/ខេត្ត បើកនៅធនាគារពាណិជ្ជដៃគូណាមួយ ឬកក់នៅធនាគារពាណិជ្ជដៃគូណាមួយ ដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមាន៖ ១.ធនាគារ អេស៊ីលីដា ភីអិលស៊ី ២.ធនាគារ កាណាឌីយ៉ា ក.អ ៣.ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា ៤.ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី ៥.ធនាគារវឌ្ឍនៈ (VattanacBank) ៦.ធនាគារ វឌ្ឍនៈអាស៊ីចំកាត់ (ABA) ៧.ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ៨.ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី ៩.ធនាគារ ដេគ្រាស់ រ៉ូយ៉ាល់ និង១០.ធនាគារ ជីបម៉ុង ខមមើសល ប៊ែង ម.ក។

បន្ទាប់ពីបានកក់ប្រាក់រួច "អ្នកទទួលការ" ត្រូវស្នើសុំអគ្គនាយកដ្ឋានរតនាគារជាតិ ចេញនូវលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា (មានទម្រង់ និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ) រួចប្រគល់ជូន "អ្នកម្ចាស់ការ" មុនពេលចុះកិច្ចសន្យា។

ការខកខានក្នុងការផ្តល់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា គឺជាមូលដ្ឋានគ្រប់គ្រាន់ក្នុងការចាត់ទុកជាមោឃៈនៃការសម្រេចប្រគល់កិច្ចសន្យា និងរឹបអូសប្រាក់កក់ធានាការដេញថ្លៃ។

ក្នុងរយៈពេល៥ (ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ បន្ទាប់ពីការប្រគល់ ទទួលសំណង់ ឬផុតសុពលភាពធានាគុណភាពសំណង់ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្ញើលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ឬធានាគារពាណិជ្ជដៃគូ ដើម្បីបង្វិលប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាជូន អ្នកទទួលការវិញ។

ក្នុងករណី "អ្នកទទួលការ" មិនបានអនុវត្តតាមប្រការណាមួយនៃកិច្ចសន្យា ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យានេះនឹងត្រូវរឹបអូសថវិកាបង់ចូលគណនីកំពង់ផែស្វយ័តភ្នំពេញ ហើយនឹងត្រូវបានកំណត់ថាជាមុខសញ្ញាសម្រាប់ការចុះឈ្មោះក្នុងបញ្ជីខ្មៅ។

**២១- ការទូទាត់**

រូបិយប័ណ្ណសម្រាប់ធ្វើការទូទាត់ គឺជាប្រាក់រៀល។ ការទូទាត់តម្លៃកិច្ចសន្យាត្រូវធ្វើតាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ ដោយបង្វែរចូលគណនីរបស់ "អ្នកទទួលការ" លេខ.......នៅធនាគារ.....។ ការទូទាត់នឹងប្រព្រឹត្តទៅបានលុះត្រាតែភាគី "អ្នកទទួលការ" អនុវត្តដាច់ខាតបានត្រឹមត្រូវតាមគំនូសប្លង់ និងបទដ្ឋានបច្ចេកទេសដែលបានចែងក្នុងកិច្ចសន្យា ដោយមានកំណត់ហេតុត្រួតពិនិត្យ វាយតម្លៃច្បាស់លាស់របស់គណៈកម្មការវាយតម្លៃនិងប្រគល់ ទទួលសំណង់ (ព្រមទាំងមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ)។

ការទូទាត់ត្រូវធ្វើតាមដំណាក់កាលដូចខាងក្រោម ៖

**ដំណាក់កាលទី១** : នៅពេលដែល "អ្នកទទួលការ" អនុវត្ត "ការងារ" សម្រេចបាន................% (................ *សរសេរជាអក្សរ*) នៃគម្រោងដែលមានចែងក្នុងកិច្ចសន្យានោះ "អ្នកម្ចាស់ការ" ត្រូវទូទាត់ជូន "អ្នកទទួលការ" នូវទឹកប្រាក់ចំនួន..................% (...............................*សរសេរជាអក្សរ*) នៃតម្លៃកិច្ចសន្យាស្មើនឹងទឹកប្រាក់ចំនួន............................................រៀល(*សរសេរជាអក្សរ*.................................................................................)។

**ដំណាក់កាលទី២** : នៅពេលដែល "អ្នកទទួលការ" អនុវត្ត "ការងារ" សម្រេចបាន..............% (.................. *សរសេរជាអក្សរ*) នៃគម្រោងដែលមានចែងក្នុងកិច្ចសន្យានោះ "អ្នកម្ចាស់ការ" ត្រូវទូទាត់ជូន "អ្នកទទួលការ" នូវទឹកប្រាក់ចំនួន...........% (*សរសេរជាអក្សរ*..................................................) នៃតម្លៃកិច្ចសន្យាស្មើនឹងទឹកប្រាក់ចំនួន..........................................................................រៀល(*សរសេរជាអក្សរ*.........................................................................................................)។

**២២- ការផាកពិន័យ**

ក្នុងករណីមានការយឺតយ៉ាវក្នុងការបញ្ចប់ "ការងារ" ដែលបណ្តាលមកពី "អ្នកទទួលការ" នោះ "អ្នកទទួលការ" ត្រូវទទួលរងនូវការផាកពិន័យចំនួន ០,១០% នៃតម្លៃកិច្ចសន្យាក្នុងមួយថ្ងៃ តាមចំនួនថ្ងៃដែលយឺតយ៉ាវ។ ទោះបីយ៉ាងណាក៏ដោយចំនួនទឹកប្រាក់ផាកពិន័យនេះមិនត្រូវឱ្យលើសពី ១០ % នៃតម្លៃកិច្ចសន្យា។ ក្នុងករណីចំនួនទឹកប្រាក់ពិន័យនេះលើសពី ១០% នោះ "អ្នកម្ចាស់ការ" អាចពិចារណាបញ្ចប់កិច្ចសន្យា។

ក្នុងករណីដែលភាគី "អ្នកម្ចាស់ការ" និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារ ជាតិ/មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ....... រតនាគារ........... ) ធ្វើការទូទាត់យឺតយ៉ាវនោះ "អ្នកម្ចាស់ការ" និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរងការពិន័យជាប្រាក់ជូន "អ្នកទទួលការ" ចំនួន ០,០៥ % ក្នុងមួយថ្ងៃលើចំនួនទឹកប្រាក់ដែលត្រូវទូទាត់តាមចំនួនថ្ងៃដែលយឺតយ៉ាវនោះ។

**២៣- ពន្ធ អាករ**

"អ្នកទទួលការ" មានកាតព្វកិច្ចបង់ជូនរដ្ឋនូវពន្ធ អាករគ្រប់ប្រភេទរួមទាំង "អាករលើតម្លៃបន្ថែម" តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ "អាករលើតម្លៃបន្ថែម" ត្រូវបង់តាម "វិធីកាត់ទុក" ដោយអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ........ នាពេលទូទាត់តម្លៃកិច្ចសន្យា។

**២៤- ការទប់ទល់ នឹងការផ្តល់លាភសក្ការៈ**

"អ្នកទទួលការ" ត្រូវប្រកាសអះអាងថាខ្លួនពុំបានផ្តល់ ឬសន្យានឹងផ្តល់ប្រាក់ចំណាយ ឬលាភសក្ការៈណាមួយចំពោះមន្ត្រីនិយោជិតរដ្ឋាភិបាលណាមួយ ឬអ្នកដេញថ្លៃណាមួយ ដើម្បីទទួលបានកិច្ចសន្យា ហើយសកម្មភាពទាំងនេះ គឺជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់ផ្អាក ឬលុបកិច្ចសន្យា។

**២៥- ការដោះស្រាយវិវាទ**

កិច្ចសន្យានេះត្រូវគ្រប់គ្រង និងត្រូវបកស្រាយតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ជម្លោះណាមួយដែលកើតឡើងរវាងភាគី "អ្នកម្ចាស់ការ" និងភាគី "អ្នកទទួលការ" អំពីលក្ខខណ្ឌដែលមានចែងក្នុង កិច្ចសន្យា ឬទាក់ទិននឹងការអនុវត្តកិច្ចសន្យា ត្រូវដោះស្រាយតាមការសម្របសម្រួលជាមុនរវាងភាគីទាំងពីរ។ ប្រសិនបើបរាជ័យនោះ ភាគីទាំងពីរត្រូវយល់ព្រមដោះស្រាយតាមរយៈមេធាវី ដោយភាគី "អ្នកម្ចាស់ការ" និងភាគី "អ្នកទទួលការ" មានសិទ្ធិជ្រើសតាំងមេធាវីម្នាក់មួយ ហើយអាជ្ញាកណ្តាលមួយរូប នឹងត្រូវតែងតាំងដោយមានការយល់ព្រមរវាងភាគីទាំងពីរ។

ប្រសិនបើ ភាគីទាំងពីរមិនយល់ស្របគ្នាលើការតែងតាំង ឬមិនឯកភាពតាមការសម្រេចរបស់អាជ្ញាកណ្តាល នោះត្រូវដោះស្រាយតាមផ្លូវតុលាការ នៃព្រះរាជាណាចក្រកម្ពុជា។

**២៦- សោហ៊ុយទាក់ទងរឿងក្តី**

ក្នុងករណីមានរឿងក្តីក្តាំកើតឡើងដែលបណ្តាលមកពីភាគី "អ្នកទទួលការ" រំលោភលើលក្ខខណ្ឌនានានៃកិច្ចសន្យាភាគី "អ្នកទទួលការ" ត្រូវទទួលខុសត្រូវចំពោះភាគី "អ្នកម្ចាស់ការ" រាល់ការចំណាយ ក្នុងការជួលមេធាវី។ ការចំណាយលើការខូចខាត និងចំណាយដទៃទៀតក្នុងរឿងក្តីនោះ ត្រូវកំណត់ដោយច្បាប់។

**២៧- ការប្រើប្រាស់ឯកសារកិច្ចសន្យា**

ប្រសិនបើ គ្មានការយល់ព្រមពីភាគី "អ្នកម្ចាស់ការ" នោះ ភាគី "អ្នកទទួលការ" មិនត្រូវប្រើប្រាស់ឯកសារកិច្ចសន្យា ឬមិនត្រូវបង្ហាញ ឬផ្តល់ព័ត៌មានដែលមាននៅក្នុងឯកសារកិច្ចសន្យា ឱ្យទៅអ្នកដទៃដឹងទេ លើកលែងតែប្រើប្រាស់ក្នុងគោលបំណងអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យា។

រាជធានីភ្នំពេញ ថ្ងៃទី ៣០... ខែ មិថុនា. ឆ្នាំ២០២២

**ប្រធានអង្គភាពលទ្ធកម្ម**

**សេង_គន្ធា**

**បានឃើញ និង ពិនិត្យត្រឹមត្រូវ**

រាជធានីភ្នំពេញ ថ្ងៃទី..៥....ខែ..កក្កដា..ឆ្នាំ២០២២

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ជួន សុខែម បានឃើញ និង ឯកភាព**

រាជធានីភ្នំពេញ ថ្ងៃទី...៦.......ខែ..កក្កដា..ឆ្នាំ២០២២

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**

**ប្រធានអគ្គនាយក**

**ហ៊ី_បាទី**

ឧបសម្ព័ន្ធទី១

**គំនូសប្លង់**

**ការខារគូស គំនូសផ្លូវ RTG គំនូសលេខ Row& Bay គំនូសទីតាំងដាក់កុងតឺន័រ នៅលើទីលាន**

**ជំហានទី១ ជំហានទី២ ស្ថិតនៅចំណតផែកុងតឺន័រ LM១៧**

**បានឃើញ និង ពិនិត្យត្រឹមត្រូវ**

រាជធានីភ្នំពេញ,ថ្ងៃទី............ខែ............ឆ្នាំ២០២២

**ប្រធានគណ:កម្មាធិការលទ្ធកម្ម**

ជួន សុខេម


20.0
RTG 10
RTG 09
RTG 08
RTG 07
RTG 06
126.0
20.0
126.0




ប្លង់កំនូសទីលានដំហានទី២

កំណត់សម្គាល់

☒ ទីតាំងអត់គូស

▬ គំនូទំហំមុខកាត់ ២០០មម

| | | | |
|---|---|---|---|
| PHNOM PENH AUTONOMOUS PORT | កំពង់ផែស្វយ័តភ្នំពេញ | | |
| | គម្រោង លាបថ្នាំទីលានស្តុកនៅចំណតផែកុងតឺន័រ LM១៧ | | |
| | គូសដោយលោក | ទី សិទ្ធិហាន | [signature] |
| | សិក្សាដោយលោក | ឃាក់ រ៉ាទី | [signature] |
| | កែសម្រួលដោយលោក | អ៊ុម ដារិទ្ធ | [signature] |
| | ពិនិត្យដោយលោក | សាយ ធន្មា | [signature] |

បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ៥ ឆ្នាំ២០២២

ប្រធានក្រុមប្រឹក្សាភិបាលឧត្តមចាត់ការ

ប្រធានអគ្គនាយក

[stamp] [signature]




លេខខាងលើ ទីលាន (ពណ៌ស)

រូបភាពមើលពីខាងលើ ទីលាន (ពណ៌លឿង)




គំនូសខាងលើ ទីលាន (ពណ៌ស) DETAIL 1




DETAIL 2




DETAIL 3

**កំពង់ផែស្វយ័តភ្នំពេញ**

ប្លង់លម្អិតគំនូសទីលាន

| គោត្តនាម និងនាម | | ហត្ថលេខា | កាលបរិច្ឆេទ | មាត្រដ្ឋាន |
|---|---|---|---|---|
| គូសដោយ | លោក ឌី សិទ្ធិហាន | | | |
| សិក្សាដោយ | លោក យ៉ិន សំ | | | មិនគិតមាត្រដ្ឋាន |
| កែសម្រួលដោយ | លោក អ៊ុំ ឆៃ | | | |
| ពិនិត្យដោយ | លោក សោម ឫទ្ធា | | | |

បានឃើញ និង ឯកភាព

ថ្ងៃ... ខែ... ឆ្នាំ២០២២

ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា ប្រធានអគ្គនាយក

# លម្អិតលក្ខណៈបច្ចេកទេស

## ការងារគូស គំនូសផ្លូវ RTG គំនូសលេខ Row& Bay គំនូសទីតាំងដាក់កុងតឺន័រ នៅលើទីលាន ជំហានទី១ ជំហានទី២ ស្ថិតនៅចំណតផែកុងតឺន័រ LM១៧

**I-គោលដៅ**

ដើម្បីសម្រួលដល់ការងារប្រតិបត្តិការក្នុងការលើកដាក់ទំនិញ ការធ្វើចរាចរណ៍ ឱ្យមានប្រសិទ្ធភាពខ្ពស់ បញ្ចៀសបញ្ហាផ្សេងៗដែលកើតឡើងជាយថាហេតុ។ សេវាដ្ឋានហេដ្ឋារចនាសម្ព័ន្ធផែ បានធ្វើការសិក្សា និង ឡើងគម្រោងលាបគំនូសផ្លូវ RTG គំនូសលេខ Row& Bay និងគំនូសទីតាំងដាក់កុងតឺន័រ នៅលើទីលាន ជំហានទី១ ជំហានទី២ ស្ថិតនៅចំណតផែកុងតឺន័រ LM១៧។

**II-លម្អិតការងារ**

**ក. ការងាររៀបចំការដ្ឋាន**

ដើម្បីឱ្យការងារនេះដំណើរការទៅបានរលូន និងមានប្រសិទ្ធិភាពខ្ពស់ អ្នកទទួលខុសត្រូវលើការងារសាងសង់ត្រូវអនុវត្តតាមចំណុចមួយចំនួនខាងក្រោមៈ

-ធ្វើការទំនាក់ទំនងជាមួយផ្នែកពាក់ព័ន្ធ ជាពិសេសអ្នកគ្រប់គ្រងទីលានដាក់ទូកុងតឺន័រដើម្បីឱ្យគាត់ជួយសម្រួលដល់ការងារនេះ។

-កំណត់ទីតាំងដែលត្រូវធ្វើ ដោយមានដាក់និមិត្តសញ្ញាបង្ហាញគ្រោះថ្នាក់ និមិត្តសញ្ញាហាមឃាត់ និងរបាំងការពារមួយចំនួន ព្រោះទីតាំងលើទីលានជាកន្លែងលើកដាក់ទំនិញ។

-ត្រូវមានឧបករណ៍គ្រប់គ្រាន់ក្នុងការងារគូសគំនូស ដោយត្រូវមានស្កុតបិទ លេខពុម្ព ខ្សែទាញតម្រង់ រ៉ូឡូ សាំងក្រអូប ស្រោមដៃ និងឧបករណ៍ដែលដំណើរការលើការងារបច្ចេកទេសនេះ។

-មុនចាប់ផ្តើមអនុវត្តការងារ ត្រូវធ្វើការបាញ់ទឹក សម្អាតទឹកថ្នាំចាស់ឱ្យបានស្អាតល្អ ធ្វើការបិទស្កុត និងតម្រង់ខ្សែមុននឹងចាប់ផ្តើមលាបទឹកថ្នាំ។

-ទឹកថ្នាំធ្វើការលាបជាមួយសាំងក្រអូប ទៅតាមទំហំស្តិចត្រឹមត្រូវ ដែលទំហំនៃការលាយត្រូវ សមស្របទៅតាមទំហំការងារដែលអាចធ្វើរួចរាល់ដោយមិនត្រូវទុកទឹកថ្នាំរហូតដល់ខូចហើយយកមកលាបទីតាំងផ្សេងទៀតនោះទេ។

-រាល់ទីតាំងដែលត្រូវលាប ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ មិនត្រូវឱ្យទឹកថ្នាំខ្ទាតចេញ ប្រឡាក់នៅលើទីលានជាដាច់ខាត។

-ក្រោយធ្វើការលាបរួចរាល់ ត្រូវធ្វើការសំអាតទីតាំងលាប ដូចជាស្កុតបិទ ដបទឹក សំរាមផ្សេងៗ ដែលបង្កឡើងឱ្យអ្នកទទួលខុសត្រូវលើការងារនេះ។

រាជធានីភ្នំពេញ,ថ្ងៃទី......៤......ខែ......កក្កដា......ឆ្នាំ២០២២

**អ្នកធ្វើគម្រោង**

ហាក់ រ៉ានី

**បានឃើញ និង ពិនិត្យត្រឹមត្រូវ**

រាជធានីភ្នំពេញ,ថ្ងៃទី......៥......ខែ......កក្កដា......ឆ្នាំ២០២២

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

ជួន សុខែម

ឧបសម្ព័ន្ធទី៣

# ពាក្យសុំដេញថ្លៃ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ................................................ ភេទ ............សញ្ជាតិ ..................ថ្ងៃខែ ឆ្នាំកំណើត.........................................ទីកន្លែងកំណើត..............................................................................................................មុខងារ.....................................តំណាងក្រុមហ៊ុន/សហគ្រាស.......................................................................................ដែលមានអាសយដ្ឋាន........................................................................................ ទូរស័ព្ទ ...........................................ទូរសារ/អ៊ីមែល ............................ គេហទំព័រ .............................. ។

## សូមគោរពជូន
## លោកជំទាវប្រធានគណៈកម្មាធិការលទ្ធកម្មកំពង់ផែស្វយ័តភ្នំពេញ

**កម្មវត្ថុ** : សំណើសុំចូលរួមដេញថ្លៃការងារគូស គំនូសផ្លូវ RTG គំនូសលេខ Row& Bay គំនូសទីតាំដាក់កុងតឺន័រ នៅលើទីលាន ជំហានទី១ ជំហានទី២ ស្ថិតនៅចំណតផែកុងតឺន័រ LM១៧។

**យោង** : សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមដេញថ្លៃការងារគូស គំនូសផ្លូវ RTG គំនូសលេខ Row& Bay គំនូសទីតាំងដាក់កុងតឺន័រ នៅលើទីលាន ជំហានទី១ ជំហានទី២ ស្ថិតនៅចំណតផែកុងតឺន័រ LM១៧។

សេចក្តីដូចមានក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមជម្រាបជូន**លោកជំទាវប្រធានគណៈកម្មាធិការលទ្ធកម្មកំពង់ផែស្វយ័តភ្នំពេញ**ជ្រាបថា ខ្ញុំបាទ/នាងខ្ញុំមានបំណងចូលរួមដេញថ្លៃការងារគូស គំនូសផ្លូវ RTG គំនូសលេខ Row& Bay គំនូសទីតាំងដាក់កុងតឺន័រ នៅលើទីលាន ជំហានទី១ ជំហានទី២ ស្ថិតនៅចំណតផែកុងតឺន័រLM១៧ ដោយដាក់តម្លៃដេញថ្លៃសរុបចំនួន...................................................................................................................................................................................................................................ចំនួនទឹកប្រាក់នេះមានបញ្ជាក់លម្អិតក្នុងបញ្ជីប៉ាន់តម្លៃ ដែលបានភ្ជាប់មកជាមួយ ។

សំណើដេញថ្លៃរបស់ខ្ញុំបាទ/នាងខ្ញុំមានសុពលភាពរយៈពេល...................(.................) ថ្ងៃបន្ទាប់ពីថ្ងៃបើកសំណើដេញថ្លៃ។

ប្រសិនបើសំណើដេញថ្លៃរបស់ខ្ញុំបាទ/នាងខ្ញុំ បានទទួលជោគជ័យនោះខ្ញុំបាទ/នាងខ្ញុំនឹងបំពេញតាមគ្រប់នីតិវិធីដែលបានកំណត់ ព្រមទាំងគោរពឱ្យបានពេញលេញនូវលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យា។

សូម លោកជំទាវប្រធាន ទទួលនូវក្តីគោរពអំពីខ្ញុំបាទ/នាងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី.............ខែ...............ឆ្នាំ២០២២

**ហត្ថលេខា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីប្រកាស
# ស្តីពីក្រមសីលធម៌លទ្ធកម្មរបស់អ្នកដេញថ្លៃ

ខ្ញុំបាទ/នាងខ្ញុំជាប្រធានក្រុមហ៊ុន/សហគ្រាស............................................................................ សូមធ្វើការអះអាងក្នុងការរៀបចំសំណើដេញថ្លៃលើ ដូចខាងក្រោម ៖

១- មិនមាននិយោជិត សហការី ភ្នាក់ងារ ម្ចាស់ភាគហ៊ុន ទីប្រឹក្សា ដៃគូ ឬញាតិសន្តានរបស់ខ្ញុំបាទ/នាងខ្ញុំមានទំនាក់ទំនងណាមួយដែលអាចចាត់ទុកថាជាទំនាស់ផលប្រយោជន៍ពាក់ព័ន្ធនឹងការដេញថ្លៃនេះទេ។

២- ប្រសិនបើខ្ញុំបាទ/នាងខ្ញុំដឹងពីលទ្ធភាពដែលអាចកើតមាននូវទំនាស់ផលប្រយោជន៍នេះ ខ្ញុំបាទ/នាងខ្ញុំ នឹងរាយការណ៍ជាបន្ទាន់ជូនស្ថាប័នអនុវត្តលទ្ធកម្ម។

៣- មិនមានការប្រព្រឹត្តអំពើពុករលួយ ក្លែងបន្លំ ឃុបឃិត ឬបង្ខិតបង្ខំ ទាក់ទិននឹងការដាក់សំណើដេញថ្លៃរបស់ក្រុមហ៊ុន/សហគ្រាសរបស់ខ្ញុំបាទ/នាងខ្ញុំ។

៤- ខ្ញុំបាទ/នាងខ្ញុំយល់ច្បាស់ពីកាតព្វកិច្ចរបស់ខ្លួន ក្នុងការអនុញ្ញាតឱ្យស្ថាប័នមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាល ឬដៃគូអភិវឌ្ឍន៍ ធ្វើអធិការកិច្ចលើរាល់លិខិតស្នាមទាំងអស់ទាក់ទងនឹងការដាក់សំណើដេញថ្លៃរបស់ក្រុមហ៊ុន/សហគ្រាសរបស់ខ្ញុំបាទ/នាងខ្ញុំនិងកិច្ចសន្យាណាមួយ ដែលជាលទ្ធផលនៃការដាក់ដេញថ្លៃនេះ ដោយមិនគិតថាក្រុមហ៊ុន/សហគ្រាសរបស់ខ្ញុំបាទ/នាងខ្ញុំបាន ឬមិនបានទទួលការសម្រេចប្រគល់កិច្ចសន្យានោះទេ។

៥- គ្មានការទូទាត់ណាមួយ ទាក់ទង នឹងដំណើរការលទ្ធកម្មនេះ ត្រូវបានធ្វើឡើងដោយខ្ញុំបាទ/នាងខ្ញុំ សហការី ភ្នាក់ងារ ម្ចាស់ភាគហ៊ុន ទីប្រឹក្សា ដៃគូរបស់ខ្ញុំបាទ/នាងខ្ញុំ ឬញាតិសន្តានរបស់ពួកគេ ទៅឱ្យភ្នាក់ងារ ទីប្រឹក្សា និយោជិត ឬញាតិសន្តានរបស់ពួកគេ ដែលចូលរួមក្នុងដំណើរការលទ្ធកម្មនេះ ជំនួសមុខឱ្យស្ថាប័នអនុវត្តលទ្ធកម្ម អតិថិជន ឬនិយោជកនោះទេ។

រាជធានីភ្នំពេញ,ថ្ងៃទី................ខែ...............ឆ្នាំ២០២២

**ហត្ថលេខា**

# បញ្ជីប៉ាន់តម្លៃសរុប

## ការងារគូស គំនូសផ្លូវ RTG គំនូសលេខ Row& Bay គំនូសទីតាំងដាក់កុងតឺន័រ នៅលើទីលាន ដំហានទី១ ដំហានទី២ ស្ថិតនៅចំណតផែកុងតឺន័រ LM១៧

| បរិយាយ | ទឹកប្រាក់ ( ជារៀល ) | ផ្សេងៗ |
|---|---|---|
| បញ្ជីលេខ ១ (ពលកម្ម)<br>បញ្ជីលេខ ២ (សម្ភារ) | ............................................<br>............................................ | |
| <u>សរុប</u> | ............................................ | |

បញ្ឈប់ត្រឹមទឹកប្រាក់ចំនួន : ....................................................................................................រៀល

(..............................................................................................................................................) ។

តម្លៃខាងលើបូកបញ្ចូល VAT(10%)

រាជធានីភ្នំពេញ ថ្ងៃទី...............ខែ...............ឆ្នាំ២០២២

**ហត្ថលេខា**

# បញ្ជីប៉ាន់តម្លៃពលកម្ម

## ការងារគូស គំនូសផ្លូវ RTG គំនូសលេខ Row& Bay គំនូសទីតាំងដាក់កុងតឺន័រ នៅលើទីលាន ជំហានទី១ ជំហានទី២ ស្ថិតនៅចំណតផែកុងតឺន័រ LM១៧

**បញ្ជីលេខ ១**

| ល.រ | ប្រភេទការងារ | ឯកតា | បរិមាណ | គិតជារៀល | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | ឯកតា | សរុប | |
| ក | **ការងាររៀបចំ និងសម្អាតការដ្ឋាន** | សម្រាប់ | 1 | | | |
| ខ | **ការងារគូសគំនូសទីលាន** | | | | | |
| ១ | គំនូសសញ្ញា + (ពណ៌លឿង) | ម² | 382 | | | |
| ២ | គំនូសសញ្ញា L (ពណ៌លឿង) | ម² | 151 | | | |
| ៣ | គំនូសសញ្ញា T (ពណ៌លឿង) | ម² | 653 | | | |
| ៤ | គំនូសលេខ (ពណ៌ស) | ម² | 242 | | | |
| ៥ | គំនូសពណ៌លឿងជាប់លើផ្លូវ RTG គូសជាប់ មុខកាត់ ២០០មម | ម² | 1,739 | | | |
| ៦ | គំនូសពណ៌សផ្លូវ RTG គូសដាច់ មុខកាត់ ២០០មម | ម² | 202 | | | |
| សរុប ខ | | | | | | |
| សរុប(ក+ខ) | | | | | | |
| អាករលើតម្លៃបន្ថែម១០%(VAT) | | | | | | |
| **សរុបតម្លៃបញ្ជីលេខ១** | | | | | | |

បញ្ឈប់ត្រឹមទឹកប្រាក់ចំនួន : ..............................................................................................រៀល

(...........................................................................................................) ។

រាជធានីភ្នំពេញ,ថ្ងៃទី................ខែ...............ឆ្នាំ២០២២

**ហត្ថលេខា**

ឧបសម្ព័ន្ធទី៤.២

# បញ្ជីប៉ាន់តម្លៃសម្ភារ

## ការងារគូស គំនូសផ្លូវ RTG គំនូសលេខ Row& Bay គំនូសទីតាំងដាក់កុងតឺន័រ នៅលើទីលាន ជំហានទី១ ជំហានទី២ ស្ថិតនៅចំណតផែកុងតឺន័រ LM១៧

**បញ្ជីលេខ ២**

| ល.រ | ប្រភេទសម្ភារ | ឯកតា | បរិមាណ | តម្លៃរាយ(៛) | តម្លៃសរុប(៛) | ប្រភព |
|---|---|---|---|---|---|---|
| ក-ការងារគូសគំនូសទីលាន | | | | | | |
| ១ | គំនូសសញ្ញា + (ពណ៌លឿង) | ម² | | | | Maestria |
| ២ | គំនូសសញ្ញា L (ពណ៌លឿង) | ម² | | | | Maestria |
| ៣ | គំនូសសញ្ញា T (ពណ៌លឿង) | ម² | | | | Maestria |
| ៤ | គំនូសលេខ (ពណ៌ស) | ម² | | | | Maestria |
| ៥ | គំនូសពណ៌លឿងជាប់លើផ្លូវ RTG គូសជាប់ មុខកាត់ ២០០មម | ម² | | | | Maestria |
| ៦ | គំនូសពណ៌សផ្លូវ RTG គូសដាច់ មុខកាត់ ២០០មម | ម² | | | | Maestria |
| សរុប ក | | | | | | |
| អាករលើតម្លៃបន្ថែម១០%(VAT) | | | | | | |
| **សរុបតម្លៃបញ្ជីលេខ២** | | | | | | |

បញ្ឈប់ត្រឹមទឹកប្រាក់ :..........................................................................................................រៀល

(.......................................................................................................................................) ។

រាជធានីភ្នំពេញ,ថ្ងៃទី................ខែ...............ឆ្នាំ២០២២

**ហត្ថលេខា**

ឧបសម្ព័ន្ធទី ៥

# ប្រតិទិនការងារ

- **រយៈពេលអនុវត្តន៍**

ការងារគូស គំនូសផ្លូវ RTG គំនូសលេខ Row& Bay គំនូសទីតាំងដាក់កុងតឺន័រ នៅលើទីលាន ជំហានទី១ ជំហានទី២ ស្ថិតនៅចំណតផែកុងតឺន័រ LM១៧អនុវត្តក្នុងរយៈពេល ៥០ថ្ងៃ ដូចមានក្នុងតារាងកាលវិភាគខាងក្រោម៖

| ល.រ | ប្រភេទការងារ | កាលវិភាគអនុវត្តការងារ | | | | |
|---|---|---|---|---|---|---|
| | | ១០ថ្ងៃ | ១០ថ្ងៃ | ១០ថ្ងៃ | ១០ថ្ងៃ | ១០ថ្ងៃ |
| ក | ការងាររៀបចំ និងសម្អាតការដ្ឋាន | | | | | |
| ខ | ការងារគូសគំនូសទីលាន | | | | | |
| ១ | គំនូសសញ្ញា + (ពណ៌លឿង) | | | | | |
| ២ | គំនូសសញ្ញា L (ពណ៌លឿង) | | | | | |
| ៣ | គំនូសសញ្ញា T (ពណ៌លឿង) | | | | | |
| ៤ | គំនូសលេខ (ពណ៌ស) | | | | | |
| ៥ | គំនូសពណ៌លឿងជាប់លើផ្លូវ RTG គូសជាប់ មុខកាត់ ២០០មម | | | | | |
| ៦ | គំនូសពណ៌សផ្លូវ RTG គូសជាប់ មុខកាត់ ២០០មម | | | | | |

រាជធានីភ្នំពេញ,ថ្ងៃទី................ខែ...............ឆ្នាំ២០២២

**ហត្ថលេខា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ .............**

**លិខិតធានា**
**ប្រាក់កក់ធានាការដេញថ្លៃ**
**សូមគោរពជូន**
**លោកជំទាវប្រធានគណៈកម្មាធិការលទ្ធកម្មកំពង់ផែស្វយ័តភ្នំពេញ**

ដោយហេតុថាក្រុមហ៊ុន/សហគ្រាស ........................................ មានបំណងដាក់សំណើដេញថ្លៃ ដើម្បីធ្វើការងារសាងសង់.......................................................................ដែលត្រូវបើកសំណើដេញថ្លៃ នៅថ្ងៃទី.......ខែ.......ឆ្នាំ.........។

អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ...................សូមធានាចំពោះមុខគណៈកម្មាធិការលទ្ធកម្ម .............នូវប្រាក់កក់ធានាការដេញថ្លៃចំនួន..............................(សរសេរជាអក្សរ...........................)។

ក្នុងករណីមានលក្ខខណ្ឌណាមួយកើតមានឡើងក្នុងចំណោមលក្ខខណ្ឌទាំងបីខាងក្រោម ៖

១- ប្រសិនបើអ្នកដេញថ្លៃ ដកសំណើដេញថ្លៃរបស់ខ្លួន ក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ

២- ប្រសិនបើអ្នកដេញថ្លៃ បដិសេធការចុះហត្ថលេខាលើកិច្ចសន្យា ក្នុងរយៈពេលសុពលភាពនៃសំណើ ដេញថ្លៃ

៣- ប្រសិនបើអ្នកដេញថ្លៃ មិនព្រមកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ។

នោះអគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ............ នឹងធ្វើការបង្វែរចូលថវិការដ្ឋនូវចំនួនប្រាក់កក់ខាងលើ នៅពេលដែលបានទទួលលិខិតស្នើសុំពីគណៈកម្មាធិការលទ្ធកម្ម ដែលបញ្ជាក់ថាអ្នកដេញថ្លៃមិនគោរពតាមលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងបីខាងលើ ។

លិខិតធានាប្រាក់កក់ធានាការដេញថ្លៃនេះមានសុពលភាព រយៈពេលយ៉ាងតិច៣០ថ្ងៃ (សាមសិបថ្ងៃ) ក្រោយសុពលភាពសំណើដេញថ្លៃ ។

................ ថ្ងៃទី............. ខែ ............. ឆ្នាំ............

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ.......**

ឧបសម្ព័ន្ធទី ៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ** .............

**លិខិតធានា**
**ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា**
**សូមគោរពជូន**
**លោកជំទាវ ប្រធានគណៈកម្មាធិការលទ្ធកម្មកំពង់ផែស្វយ័តភ្នំពេញ**

ដោយហេតុថាក្រុមហ៊ុន/សហគ្រាស........................................................ បានទទួលលិខិតស្តីពីការចុះកិច្ចសន្យាការងារសាងសង់...................... លេខ ............. ចុះថ្ងៃទី........ ខែ ........... ឆ្នាំ............. ដែលមានតម្លៃកិច្ចសន្យាចំនួន........................... (សរសេរជាអក្សរ..................................) ។

ដោយមានចែងនៅក្នុងលិខិតស្តីពីការចុះកិច្ចសន្យាថា "អ្នកទទួលការ" ត្រូវផ្តល់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ............. ដែលមានតម្លៃទឹកប្រាក់ស្មើនឹង១០% (ដប់ភាគរយ) នៃតម្លៃកិច្ចសន្យាសរុប ដើម្បីធានាការអនុវត្តកាតព្វកិច្ចស្របតាមលក្ខខណ្ឌកិច្ចសន្យា ។

អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ......... សូមធានា និងទទួលខុសត្រូវ នូវប្រាក់កក់ចំនួន ........................ (សរសេរជាអក្សរ .................................................) ។

ប្រាក់កក់ខាងលើនេះ នឹងត្រូវបង្វែរចូលថវិការដ្ឋ នៅពេលបានទទួលលិខិតស្នើសុំពី "អ្នកម្ចាស់ការ" ដែលបញ្ជាក់ថា "អ្នកទទួលការ" មិនគោរពតាមលក្ខខណ្ឌនៃកិច្ចសន្យា ហើយក្រុមហ៊ុន/សហគ្រាស ............................................................... គ្មានសិទ្ធិប្រកែក ឬតវ៉ាឡើយ ។

លិខិតធានានេះមានសុពលភាពរហូតដល់ក្រោយរយៈពេលធានាគុណភាពសំណង់ជាស្ថាពរ ។

.............. ថ្ងៃទី ............ ខែ........... ឆ្នាំ...........
**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ**............

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## សេចក្តីប្រកាស

## ស្តីពីក្រមសីលធម៌លទ្ធកម្មរបស់គណៈកម្មាធិការលទ្ធកម្ម

**យើងខ្ញុំសូមធ្វើការអះអាងថា ៖**

១- ក្នុងអំឡុងពេលដំណើរការលទ្ធកម្ម និងការវាយតម្លៃសំណើដេញថ្លៃ យើងខ្ញុំប្រកាន់ខ្ជាប់នូវក្រមសីលធម៌លទ្ធកម្មដូចមានបញ្ជាក់នៅក្នុងសៀវភៅលទ្ធកម្ម ស្តីពីការអនុវត្តវិធាននិងបទប្បញ្ញត្តិ ស្តីពីលទ្ធកម្មសាធារណៈ។

២- នៅក្នុងការអនុវត្តតួនាទីរបស់យើងខ្ញុំ យើងខ្ញុំពុំទទួលនូវផលប្រយោជន៍ ទោះជារូបិយវត្ថុ ឬជាសម្ភារពីសំណាក់ស្ថាប័នខាងក្រៅ អ្នកដេញថ្លៃ ឬទីប្រឹក្សាណាមួយនោះទេ ក្រៅអំពីប្រាក់បៀវត្សផ្លូវការដែលយើងខ្ញុំបានទទួលក្នុងឋានៈជាមន្ត្រីរាជការ។

៣- តាមដែលយើងខ្ញុំបានដឹង គ្មានសហសេវិក សហការី ឬញាតិសន្តាន បានទទួលនូវផលប្រយោជន៍ ទោះជារូបិយវត្ថុ ឬជាសម្ភារពីសំណាក់ស្ថាប័នខាងក្រៅ អ្នកដេញថ្លៃ ឬទីប្រឹក្សាណាមួយនោះទេក្រៅអំពីប្រាក់បៀវត្សផ្លូវការ។

៤- យើងខ្ញុំមិនបានដឹងអំពីការអនុវត្តដែលកេងបន្លំ ពុករលួយ ឃុបឃិត ឬបង្ខិតបង្ខំនានា ដែលបានកើតឡើង នៅក្នុងដំណើរការលទ្ធកម្មនោះទេ ហើយយល់យ៉ាងច្បាស់ថា យើងខ្ញុំមានកាតព្វកិច្ចខាងសីលធម៌ ក្នុងការរាយការណ៍អំពីការអនុវត្តបែបនេះ ប្រសិនបើយើងខ្ញុំបានដឹង។

៥- គ្មានទំនាស់ផលប្រយោជន៍ណាមួយកើតឡើង ទោះជាចំពោះយើងខ្ញុំ ឬចំពោះអ្នកដេញថ្លៃ ឬទីប្រឹក្សាដែលត្រូវបានសម្រេចប្រគល់កិច្ចសន្យាឱ្យ ឬចំពោះសហសេវិក សហការី និងញាតិសន្តាននោះទេ។

រាជធានីភ្នំពេញ ថ្ងៃទី ............ខែ ................ ឆ្នាំ២០២២

**- លោកជំទាវ ជួនសុខេម**

**- លោក ហ៊ីន សុខាល័យ**

**- កញ្ញា ឈាវ វណ្ណធា**

**- លោក សាយ ចន្ថា**

**- លោកស្រី សេង គន្ធា**